# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សម្ភាសជាមួយឈ្មោះ នង ចាន់ផល ភេទប្រុស អាយុ៣៩ឆ្នាំ*
## *អតីតកុមារដែលមានជីវិតពីគុកទួលស្លែង*
## *សព្វថ្ងៃរស់នៅសហគមន៍ជីត្រុំ សង្កាត់បឹងជំពន់ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ*
## *សម្ភាសនៅភូមិតាំងតាឡាត់ ឃុំក្តាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ*
## *នៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៩*
## *សម្ភាសដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ជី ទេរិទ្ធ*
## *សរុបៈ ២៨ទំព័រ*

ដារ៉ា ៖ ខ្ញុំឈ្មោះដារ៉ា ហើយទេរិទ្ធ ចង់មកជួបបង ចង់មកសួរនាំពីជីវិតផ្ទាល់ខ្លួនរបស់បង ដែលរស់នៅក្នុងរបបប៉ុលពត របបខ្មែរក្រហម។ ហើយដំបូងខ្ញុំចង់ស្គាល់ឈ្មោះបងសិន បងឈ្មោះអីដែរ?

ចាន់ផល ៖ ខ្ញុំឈ្មោះនង ចាន់ផល ឆ្នាំ១៩៧៥ត្រូវបានខ្មែរក្រហមជម្លៀសឲ្យចេញពីភូមិដំណាក់ស្នួល ស្រុកជុំគីរី ខេត្តកំពត ឲ្យទៅរស់នៅក្នុងស្រុកភ្នំស្រួច ស្រុកត្រែងត្រយឹង ខេត្តកំពង់ស្ពឺ។ កាលនោះខ្ញុំនៅកុមារភាព។

ដារ៉ា ៖ ៖ តែកាលជម្លៀសនឹង បងជម្លៀសពីភូមិស្រុកកំណើតបងតែម្តង?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ៖ ស្រុកកំណើតបងនៅណា?

ចាន់ផល ៖ ស្រុកខ្ញុំនៅភូមិដំណាក់ស្នួល ឃុំស្រែចែង ស្រុកជុំគីរី ខេត្តកំពត។

ដារ៉ា ៖ ៖ នៅខេត្តកំពត?

ចាន់ផល ៖ បាទ! នៅជាយខេត្តកំពត និងខេត្តតាកែវ។

ដារ៉ា ៖ ៖ នៅពេលដែលជម្លៀសនឹង ជម្លៀសពីភូមិនឹងមកខាងកំពង់ស្ពឺនេះ?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ៖ កាលជម្លៀសនឹង ជម្លៀសទាំងក្រុមគ្រួសារបង?

ចាន់ផល ៖ បាទ! ជម្លៀសទាំងក្រុមគ្រួសារ ប៉ុន្តែកាលនោះខ្ញុំនៅក្មេងវាចាំអស់សូវច្បាស់ កាលនោះ ថាជម្លៀសតែម្តង។

ដារ៉ា ៖ ៖ ចុះពេលមកដល់ ជម្លៀសមកដល់កំពង់ស្ពឺនឹង ក្រុមគ្រួសាររបស់បងមកនៅជុំគ្នា?

ចាន់ផល : បាទ! នៅជុំគ្នា គេបំបែកទៅដាក់ខាងប្ដី និងមនុស្សចាស់ និងកុមារដាក់ផ្សេងគ្នា ។

ដារ៉ា : : ពេលដែលបំបែក បងបានរស់នៅជាមួយក្រុមគ្រួសារដែរ?

ចាន់ផល : ខ្ញុំនៅក្នុងកងកុមារគេមើល ។

ដារ៉ា : : នៅក្នុងកងកុមារ ចុះឪពុកម្ដាយបងរស់នៅស្ថានភាពម៉េច?

ចាន់ផល : បាទ! រស់នៅស្ថានភាពផ្សេងពីគ្នា បែកគ្នា ។

ដារ៉ា : : មានន័យថា ម្ដាយបងនៅផ្សេង ឪពុកបងនៅផ្សេង ហើយបងនៅកងកុមារផ្សេងទៅ?

ចាន់ផល : បាទ!

ដារ៉ា : : ហើយដែលជួបជុំគ្នាទេ ម្ដងម្កាល់?

ចាន់ផល : ជួបជុំម្ដងម្កាល់ លើកលែងតែខ្ញុំលួចចេញពីកន្លែងកងកុមារទៅ រត់ទៅ ទៅជួបម្ដាយ ពេលទៅបានជួបទាល់តែរត់ទៅ ។

ដារ៉ា : : ពេលរត់ទៅជួបម្ដងៗ ទៅជួបម្ដាយៗឪពុកអីថាប្រាប់ណែនាំម៉េចដែរ?

ចាន់ផល : គាត់តែងតែមាន ច្រើនគាត់បញ្ជូនមកកន្លែងកងកុមារវិញ ដូនកាលរត់ទៅជួបឪពុកៗ គាត់ចាប់បញ្ជូនយកមកវិញ ខ្លាចអង្គការគេស្ដីបន្ទោសថាកូនចៅទៅនៅ រត់ទៅនៅផ្ទះ នៅតាមគាត់ផ្ដល់អីអញ្ចឹង ឲ្យមកនៅកន្លែងកងកុមារ ។

ដារ៉ា : : ចុះម្ដាយបងឈ្មោះអីដែរ?

ចាន់ផល : ម្ដាយខ្ញុំឈ្មោះ មុំ យ៉ូវ ។

ដារ៉ា : : ចុះឪពុក?

ចាន់ផល : ឪពុកឈ្មោះ នង ជិន ។

ដារ៉ា : : គាត់ទាំងពីរនៅរស់ទេ?

ចាន់ផល : គាត់ស្លាប់ហើយ ស្លាប់នៅយើងទួលស្វែង ។

ដារ៉ា : : ចុះពេលរស់នៅជាកងកុមារ បងមានកុមារច្រើន ហើយការរស់នៅ ការហូបចុកអីម៉េចដែរ?

ចាន់ផល : នៅកងកុមារដាក់កន្លែងប្រមូលផ្ដុំមួយ ហើយការហូបចុកវាអត់ដិតដល់ដូចយើងបច្ចុប្បន្ននេះ ការរស់នៅដូចជាហូបជារួម បាយគេដាំបាយលាយដំឡូងៗមី មានឆៅខ្លះ ដូនណាយើងហូបទៅវាធ្វើឲ្យរាគរូសម្ដងគេម្ដងម្កាល ដំឡូងវានៅឆៅចម្អិនមិនល្អ ។

ដារ៉ា : : នៅក្នុងនឹង ដូចថាគេមានអនុញ្ញាតិឲ្យ អ្នកគ្រប់គ្រងកន្លែងកងកុមារបង មានអនុញ្ញាតិឲ្យក្មេងទៅលេងឪពុកម្ដាយ ឬឪពុកម្ដាយមកលេងទេ?

ចាន់ផល : ដូចអត់មានអនុញ្ញាតិអីផង កាលនោះចន្លោះចិត្តចង់ទៅរត់ទៅតែម្តង រត់ដោយមិនខ្លាចការដាក់ទារុណកម្ម យើងរត់ទៅជួបគាត់ កាលនោះយើងនៅក្មេង យើងជិនះទៅ ដូចថា យើងមិនសូវដឹងពីការធ្វើបាបយ៉ាងណាដែរជួនណាមានការសំលុតការអីអញ្ចឹងវៃដងអីខ្លះ ។

ដារ៉ា : : ពេលដែលដល់របបខ្មែរក្រហម ដែលចូលមកកាន់កាប់ប្រទេសឆ្នាំ៧៥ បងអាយុប្រហែលប៉ុន្មានហើយ?

ចាន់ផល : មកដល់ឆ្នាំ៧៥ ខ្ញុំអាយុបាន៥ឆ្នាំ ។

ដារ៉ា : : ៥ឆ្នាំ?

ចាន់ផល : បាទ!

ដារ៉ា : : ៥ឆ្នាំនឹង បងអាចធ្វើការងារបានទេ?

ចាន់ផល : ធ្វើការបានដោយសារ ធ្វើការតិចតួចដូចជាលើកដីលើអីនេះ តាមតែកងកុមារយើងឲ្យធ្វើនឹង ដូចលើកទំនប់តិចតួចនឹង ហើយខ្ញុំកូនក្មេងមិនសូវធ្វើអីច្រើនជាងគេទេ ច្រើនយំច្រើនអីអញ្ចឹង ។

ដារ៉ា : : ច្រើនធ្វើអីខ្លះ?

ចាន់ផល : ដូចជាលើកដី កាប់ដីដាក់បង្គីរ ដាក់ទំនប់ ធ្វើភ្លឺស្រែនឹង ហើយជួនកាលរកជី ។

ដារ៉ា : : បងដឹងថាអ្នកណាប្រធានកងកុមារ?

ចាន់ផល : មានបុរសម្នាក់ឈ្មោះយ៉ុង១ ប៉ុន្តែគាត់ជាមេកងកុមារនឹង គាត់ទទួលខុសត្រូវមើលក្មេង១

ដារ៉ា : : ហើយកាលនឹងកងកុមារបងនៅត្រង់ណា ម្តុំណា?

ចាន់ផល : នៅភូមិត្រែងត្រយឹងនឹង ខេត្តកំពង់ស្ពឺ ប្រហែលផ្លូវបំបែកជា៤ អាផ្លូវមួយទៅគិរីរម្យ ផ្លូវមួយទៀតយើងទៅត្រពាំងកោះស្លា ផ្លូវមួយទៀតទៅភ្នំ ។

ដារ៉ា : : ចុះពូអាចរៀបរាប់បានទេ ពេលណាដែលពូមកដល់គុកទួលស្លែង ហើយមកយ៉ាងម៉េច អីយ៉ាងម៉េច?

ចាន់ផល : កាលមកនឹង ត្រូវបានគេនឹងប្រធានខ្មែរក្រហមគេនឹងចំនួន៥-៦នាក់ ប្រហែល៧-៨នាក់នឹង គេមានរថយន្តមួយ១ មុនដំបូងមកតែខ្មែរក្រហម៤នាក់ទេ សុទ្ធតែស្លៀកពាក់ខោអាវខ្មៅ មកយកឪពុកខ្ញុំទៅមុនចំនួនប្រហែលជា៦ខែ បានយកម្តាយខ្ញុំហើយនឹងខ្ញុំ ។ ៦ខែក្រោយ ប្រហែល៣ខែក្រោយ តាមការស្មានរបស់ខ្ញុំអត់ចាំ ហើយយកម្តាយខ្ញុំនិងប្អូន១ខ្ញុំមកទៀត មកចូលទួលស្លែង មិនចូលភ្លាមមកភ្លាមទេ មកសម្រាកនៅនឹងរ៉ាវទេះភ្លើងបាន៣យប់៣ថ្ងៃ ។ ហើយបន្ទាប់មក បានយកចូលគុកទួលស្លែងនៅពេលយប់

ម៉ោង៧ ហើយពេលនឹងមានការសំឡុតរុញច្រានទាត់ធាក់ម្ដាយខ្ញុំនឹង បានខ្ញុំមានអារម្មណ៍ថានៅកន្លែងនេះ មិនមែនជាកន្លែងល្អទេ ឬកន្លែងណាមួយ មានរឿងអីហើយ បានជាគេរុញម្ដាយយើងខ្ទប់ជញ្ជាំង ឲ្យគាត់ឈរថតពីចំហៀង ពីមុខ ឲ្យវាស់កំពស់ ហើយអ្នកធ្វើការកត់ឈ្មោះកត់អីនៅលើក្រដាស នៅពេលក្បាលល្ងាច ប្រហែលជាពេលយប់ម៉ោង៦-៧យប់នឹង ។

ដារ៉ា : : ចុះពេលដែលពួកខ្មែរក្រហមមានកាំភ្លើងមានអី ទៅយកឪពុកបងមកនឹង បងដឹង បងបានឃើញ កាលដែលយកឪពុក?

ចាន់ផល : កាលយកឪពុកមកនឹងអត់បានឃើញទេ ប៉ុន្តែពូខ្ញុំគាត់នៅទីនោះដែរ ពូខ្ញុំរត់មកប្រាប់ម្ដាយថាគេចាប់ ពូរត់មកប្រាប់ម្ដាយខ្ញុំថា «គេចាប់បងគេចង គេឲ្យបងទៅរៀនសូត្រនៅភ្នំពេញហើយ» ។

ដារ៉ា : : អញ្ចឹង?

ចាន់ផល : បាទ!

ដារ៉ា : : ហើយពូរបស់បងឈ្មោះអី?

ចាន់ផល : ឈ្មោះពូច្រឹប ។

ដារ៉ា : : ហើយគាត់រស់នៅទេ សព្វថ្ងៃ?

ចាន់ផល : ស្លាប់ហើយ នៅជិទាន់ពេលបែកនឹង ពេលជិទាន់ពេលកងទ័ពវៀតណាមរំដោះបាន ពេលខ្មែរក្រហមរត់ៗហើយខ្មែរក្រហមគ្នាឯងនឹងបាញ់សម្លាប់គ្នាឯងទៀត បាញ់សម្លាប់ប្រជាពលរដ្ឋឯងទៀត ។ ពូខ្ញុំត្រូវបានគេបាញ់ដោយកាំភ្លើងស្វ័យប្រវត្តិ បាញ់ចំពីក្រោយខ្នងចំនួនប្រហែលជា១០គ្រាប់ ហើយខ្ញុំមិនសូវដឹង ។

ដារ៉ា : : ហើយពូមកប្រាប់ម្ដាយរបស់បងទេ ដែលថាពួកខ្មែរក្រហមមកឲ្យពុកបងទៅរៀនសូត្រនៅភ្នំពេញ?

ចាន់ផល : បាទ! គាត់ទៅប្រាប់ខ្ញុំទៅ ខ្ញុំនៅក្បែរម្ដាយខ្ញុំពូ ពេលទៅម្ដាយខ្ញុំមានការខ្វាយខ្វល់ មានបារម្ភច្រើន ។ ហើយក្រោយមករយៈពេលប្រហែលជា៣ខែជាង តាមមើល៣ខែ៤ខែនឹង ពេលនោះថាមានរថយន្ត២គ្រឿងទៀតមកយកម្ដាយខ្ញុំ ហើយមានទាហានខ្មែរក្រហមស្លៀកពាក់ខ្មៅមកដែរ ដោយព្រមទាំងនៅក្នុងនោះមានស្ត្រី២នាក់ និងកូនម្នាក់មកទៀត រួមជាមួយខ្ញុំនិងម្ដាយខ្ញុំ ហើយប្អូន៤នាក់ទៀត បានឡើងជិះរថយន្តមកកាន់ភ្នំពេញ ។

ដារ៉ា ៖ ពេលខ្មែរក្រហមមកយកម្ដាយបងនឹង បានប្រាប់យ៉ាងម៉េចទេ?

ចាន់ផល ៖ គេបានប្រាប់ច្រើន ប៉ុន្តែខ្ញុំអត់បានចាំ ដោយព្រោះម្ដាយខ្ញុំគាត់ភ័យផង ហើយម្ដាយខ្ញុំគាត់ឈឺហើមទៀត គាត់មានជម្ងឺហើមជើងហើមដៃដោយខ្វះជីវជាតិ ហើយខ្ញុំដឹងថាគាត់ឈឺហើមដើរអត់ចង់រួចទេ ហើយក៏បានឡើងឡានព្រមជាមួយពួកទាហានទាំងអស់នោះមក ។

ដារ៉ា ៖ មានន័យថាពេលដែលឡានពួកខ្មែរក្រហមមកយកម្ដាយរបស់បងនឹង នៅក្នុងឡាននឹងមានស្ត្រី២នាក់ ហើយមានកូនស្រីម្នាក់ហើយ?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ហើយតាមផ្លូវមក បងមានបានសួរនាំ ឮម្ដាយបងសួរនាំស្ត្រីនឹងនៅណា ឈ្មោះអី?

ចាន់ផល ៖ អត់មាននិយាយទេ គ្រាន់ឡើងលើឡានមក ទាំងទាហានខ្មែរក្រហម ហើយនឹងអ្នកជិះខាងក្រោយនឹង គឺអត់មាននិយាយចូលគ្នាទាំងអស់ ជិះស្ងាត់ឈឹង ។

ដារ៉ា ៖ កាលមកយកម្ដាយបង បងនៅណា នៅជាមួយម្ដាយដែរ ឬក៏ទៅហៅពីកង?

ចាន់ផល ៖ ខ្ញុំនៅកងកុមារ ចៃដន្យអីកាលនឹងខ្ញុំរត់មកនៅជាមួយម្ដាយ ។ បានប្រហែលជាមួយថ្ងៃបានគេមានទាហានខ្មែរក្រហមនឹងមកយកម្ដាយខ្ញុំ ចៃដន្យអីខ្ញុំនៅនឹងដែរ ខ្ញុំមកពីកងកុមារ ខ្ញុំមកពីកងកុមារ ។

ដារ៉ា ៖ ចុះប្អូនបង៣នាក់ទៀតនឹង នៅកន្លែងណាដែរថាពេលខ្មែរក្រហមទៅយកម្ដាយបង គឺនៅជុំគ្នា?

ចាន់ផល ៖ បាទ! នៅជុំគ្នាអញ្ចឹង ។

ដារ៉ា ៖ មានន័យថា ប្អូនបង៣នាក់ទៀត អត់បែកចេញពីឪពុកម្ដាយទេ?

ចាន់ផល ៖ បាទ! អត់បែកទេ ។

ដារ៉ា ៖ ដោយសារតែក្មេងពេក ឬក៏?

ចាន់ផល ៖ ដោយសារតែក្មេងពេក ហើយនឹងម្ដាយខ្ញុំឈឺផង ដាក់នៅរួមគ្នា ។

ដារ៉ា ៖ អញ្ចឹងក្នុងបងប្អូនបង មានតែបងម្នាក់ទេ ដែលមកនៅកងកុមារ?

ចាន់ផល ៖ បាទ! ហើយនឹងបងប្រុសដទៃទៀតគេនៅតាមសហករណ៍ផ្សេងៗទៀត គេនៅតាមសហករណ៍ផ្សេងៗទៀត ។

ដារ៉ា ៖ បងមានបងប្អូនប៉ុន្មាននាក់?

ចាន់ផល ៖ បងប្អូនបើតាមរាប់ទាំងអ្នកនៅរួលស្លែង៨នាក់ ទាំងអស់៩នាក់ ។

ដារ៉ា ៖ បងមានបងប្អូនបង្កើត៩នាក់?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ហើយបង៥នាក់ផ្សេងទៀត គាត់ធំៗហើយ?

ចាន់ផល ៖ គាត់ធំៗហើយនៅខាងក្រៅ អត់មាននៅជាមួយឪពុកម្តាយក្នុងជំនាន់នឹងទេ គាត់នៅខេត្តតាកែវ ខ្លះខាងខេត្តកំពតខ្លះ ខាងស្រែអំបិលខ្លះ សហករណ៍ស្រែអំបិល ។

ដារ៉ា ៖ ហើយនៅជាមួយម្តាយនឹង៣នាក់ ហើយបងនៅកងកុមារ?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ពេលដែលបងមកលេងឪពុកម្តាយមួយថ្ងៃនឹង គឺចំពេលដែលពួកខ្មែរក្រហមមកយកម្តាយបងតែម្តង មែនទេ?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ពេលគេយកម៉ោងប៉ុន្មាន?

ចាន់ផល ៖ ខ្ញុំប្រហែលជាម៉ោង បើតាមខ្ញុំស្មាន ប្រហែលជាម៉ោង២ម៉ោង១ ម៉ោង២ថ្ងៃត្រង់ ប៉ុនអត់នៅចាំថ្ងៃខែទេ បើកាលនោះនៅក្មេងពេក ហើយអត់មានបានរៀនចេះអីផង ។

ដារ៉ា ៖ ហើយដែលយកម្តាយបងមកនឹង អត់មានប្រាប់ថាមកនឹងអីម៉េចទេ?

ចាន់ផល ៖ គ្រាន់ថាត្រូវបានបញ្ជូន ដូចអត់មានអីផង ដដែកជាមួយម្តាយខ្ញុំ ខ្ញុំអត់បានស្តាប់ឮ គ្រាន់តែដដែកហើយម្តាយខ្ញុំប្រមូលខ្ញុំនឹងឲ្យឡើងឡានជាមួយគេចេញទៅ ។

ដារ៉ា ៖ ពេលមកដល់ភ្នំពេញនេះ បងមិនទាន់ចូលដល់ទួលស្លែងភ្លាមទេ?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ហើយទុកម្តុំណាទៅ?

ចាន់ផល ៖ ស្នាក់នៅវ៉ារទេះភ្លើង៣ថ្ងៃ៣យប់ ហើយក្រោយមកបានចូលទួលស្លែងប្រហែលជាពេលថ្ងៃល្ងាចប្រហែលម៉ោង៦-៧យប់ ហើយពេលនោះនៅព្រិលនៅមើលឃើញមុខគ្នាស្គាល់

ដារ៉ា ៖ ដាក់កន្លែងវ៉ានឹង ៣ថ្ងៃ៣យប់នឹង មានមនុស្សអីច្រើនទេនៅកន្លែងវ៉ានឹង?

ចាន់ផល ៖ វ៉ានឹង មានទាហានខ្មែរក្រហមស្លៀកពាក់ខ្មៅ ឃើញដើរខ្វាត់ខ្វែងដែរ ប៉ុនអត់មានច្រើនប៉ុន្មាន ហើយប្រហែលជាមនុស្ស៤-៥នាក់ឃើញដើរយាមនៅក្នុងហ្នឹង ។

ដារ៉ា ៖ តែប្រជាពលរដ្ឋ តែជាជនរងគ្រោះដែលចាប់មកជាមួយបងដែរនឹង មានឃើញគ្នាច្រើនទេ?

ចាន់ផលៈ អត់ទេ ឃើញជនក្នាប៉ុន្មាននាក់មកជាមួយឡាននឹង ហើយចំណាស់២នាក់ ម្ដាយខ្ញុំ ហើយនឹងយាយ៨នាក់ទៀត ហើយកូនក្មេងគេខាងនោះវ័យចំណាស់២នាក់ទៀតនឹងកូនមួយ ។

ដារ៉ា : : ២នាក់ទេ?

ចាន់ផល : បាទ!

ដារ៉ា : : ហើយពេលដែលទុកនៅកន្លែងវ៉ារទេះភ្លើង២-៣ថ្ងៃអញ្ចឹង ការហូបចុកការអីយ៉ាងម៉េចដែរ?

ចាន់ផល : បាទ! ឃើញគេយកបាយឲ្យហូបដែរនឹង រៀងរាល់ពេលដែរ ។

ដារ៉ា : : ពេលនឹងបងឃើញចរិតពួកខ្មែរក្រហមយ៉ាងម៉េចដែរ ធ្វើឡើងទៅលើក្រុមគ្រួសារបង?

ចាន់ផល : ដូចមានសម្ដីបោះពាក្យសម្ដីគ្រោតគ្រៀត ដូចមានដាក់បាយ ទម្លាក់ឆ្នាំង ទម្លាក់ឲ្យយើងអញ្ចឹងដូចថាអត់មានទទួលការគួរសមទេណា ដូចនិយាយគំហកៗ ។ ហើយពាក្យសម្ដីមិនដឹងនិយាយថាម៉េច បើខ្ញុំនៅក្មេងអត់ទាន់ចាំទេ ។

ដារ៉ា : : បន្ទាប់មកហៅបងឡើងឡាន ដែលបងថាមកទួលស្លែងនឹង ហៅយ៉ាងម៉េចអីម៉េច?

ចាន់ផល : ហៅនឹងដូចហៅមិនមានការគំរាមកំហែងអី ដូចពាក្យធម្មតា ហៅនិយាយធម្មតា ។

ដារ៉ា : : ហើយឡានដែលដឹកទៅទួលស្លែង ជាឡានដដែល ដែលដឹកមកពីភូមិ?

ចាន់ផល : បាទ! ឡានមកដល់ទួលស្លែងមានអ្នកផ្សេងទៀត យកពីវ៉ារទេះភ្លើងនឹង ទៅបញ្ចូលទួលស្លែងនឹងបណ្ដោយ ។

ដារ៉ា : : ហើយការដែលយកនឹង បងមានឃើញខ្មែរក្រហមហុចជាសំបុត្រជាអីបញ្ជាក់ ឬក៏គ្រាន់ទៅដល់ហៅបងទៅ?

ចាន់ផល : បាទ! មានអ្នកបើកឡាននឹងគេកាន់ក្រដាសនឹងមួយ ហុចទៅឲ្យអ្នកនៅក្នុងគុកនឹង ។

ដារ៉ា : : នៅកន្លែងវ៉ានឹង?

ចាន់ផល : បាទ! គេហុចពេលមកគេហៅឡើងឡាន មកដល់ចូលក្នុងគុកមានគេអ្នកកាន់ក្រដាសនឹងហុចឲ្យអ្នកគុកទួលស្លែងនឹង ហើយបានគេហៅចូលទៅក្នុងប៉ុយរូ ចូលទៅក្នុងទីចាត់ការនឹងនៅរាល់ថ្ងៃ ហើយចូលទៅមានជាងថត មានអ្នកសរសេរកត់ឈ្មោះ ចូលទៅថត ឃើញថតចំហៀង ហើយនឹងថតពីមុខ និងមានកាន់ផ្លាក់លេខ ផ្លាកសនឹងមិនដឹងថាលេខប៉ុន្មានទេ ខ្ញុំអត់បានចាំ ។ ខ្ញុំឃើញមានការផ្សរច្រើនទាត់ធាក់ម្ដាយផង និងដទៃៗទៀត២នាក់ដោយ

និយាយពាក្យអសុរសទៅគាត់ ដូចជាមីនេះមីនោះរុញច្រានបុកជញ្ជាំង ហើយខ្ញុំមានការភ័យខ្លាច ប៉ុន្តែប្អូនខ្ញុំអត់ដឹងប្អូនខ្ញុំនៅតូច រត់ទៅលិចរត់ទៅកើតរត់លេងធម្មតា ។

ដារ៉ា : : ពេលឡើងជិះឡានពីរ៉ាមក មានដាប់ចំណងអី?

ចាន់ផល : អត់មានដាក់ចំណង អត់មានត្រូវចង អត់មានធម្មតាឡើងមក ។

ដារ៉ា : : ហើយពេលមកដល់ទួលស្លែងមានការរុញច្រាន មានការប្រើពាក្យសម្តីមិនគួរសម មានការថតរូបថតអីហើយ បន្តទៀតគេធ្វើម៉េចអីយ៉ាងម៉េច?

ចាន់ផល : គេរុញទៅអគារទី៣ អគារយើងបែរមុខមកខាងមុខ អគារបើរាប់ទៅអគារទី៣ រុញឡើងជាន់ទី២ទៅដេកនៅបន្ទប់ទី២ ហើយទ្វារបិទជិត វារុញឡើងលើក្តារងើលហើយ ចូលសម្រានទៅ ហើយអ្នកយាមគុកគេចាក់សោរខាងក្រៅ ។

ដារ៉ា : : ចុះម្តាយបងនោះ?

ចាន់ផល : ម្តាយខ្ញុំនៅចូលជាមួយគ្នាទាំងអស់ ទាំងអ្នកមកទាំងអស់គ្នានឹង ។

ដារ៉ា : : អញ្ចឹងមួយវេននឹង មានម្តាយបង ហើយនឹងបងប្អូនបង៤នាក់ ហើយនឹងស្ត្រី២នាក់និងកូនមួយ?

ចាន់ផល : បាទ!

ដារ៉ា : : អញ្ចឹងម៉ាក្រុមនឹងចូលក្នុងបន្ទប់តែមួយទេ?

ចាន់ផល : បាទ! ចូលបន្ទប់តែមួយហើយ បានគេជម្រៀសខ្ញុំទៅណាៗ ហើយម្តាយខ្ញុំគាត់ដឹងរឿងមិនដឹងទេ គាត់គ្រាន់ថាមើលប្អូនផង ។ អញ្ចឹងខ្ញុំនាំគ្នាដើរប្រមូលចុះ ក្មេងតូចៗអ្នកយាមនោះកាន់ចុះមកបីកាន់មកខាងក្រោយគុកនឹង បរិវេណក្រោយគុកកន្លែងដាងធ្វើឃ្នោះ ធ្វើអីខាងក្រោយនឹង ។

ដារ៉ា : : ហើយពេលនឹងម្តាយបង អញ្ចឹងពេលនឹងដែលបងបែកពីម្តាយបងមក?

ចាន់ផល : បាទ! បែកម្តាយតាំងពីចាប់បែករហូតមក ។

ដារ៉ា : : ហើយចុះកំឡុងពេលដែលបងមកដល់ទួលស្លែងអីនឹង នៅជាមួយម្តាយបងអី ឬក៏មកតាមដំណើរមកដល់ទួលស្លែង ម្តាយបងមាននិយាយអីពីឪពុកបងទេ?

ចាន់ផល : ម្តាយខ្ញុំអត់មានហ៊ាននិយាយអីទេ គាត់មានការភ័យខ្លាច គាត់អត់មាននិយាយសម្តីអីចេញទាំង គ្រាន់តែស្ងាត់ ប៉ុនពេលយប់គាត់អត់បានសម្រានទេ គាត់ហាក់ដូចជាមានការគិតច្រើន ហើយគាត់តែងតែអង្អែលក្បាលពួកខ្ញុំជាកូនៗដែលសម្រានជិតគាត់ ។ ហើយគាត់ដកដង្ហើមធំៗមែនទែន អត់មានការនិយាយស្តីអីទេ ។

ដារ៉ា ៈ ៈ  អត់មាននិយាយស្តីទេ?

ចាន់ផល ៈ  បាទ!

ដារ៉ា ៈ ៈ  ហើយកាលនោះបងយំអីដែរ ពេលដែលនៅជាមួយម្តាយ ពេលយប់នឹង?

ចាន់ផល ៈ  ដូចអត់មានទេ យំតែប្អូនខ្ញុំ ។

ដារ៉ា ៈ ៈ  ហើយពេលយំឮឡាអញ្ចឹង មានសម្លេងខ្មែរក្រហមនៅក្នុងគុកនឹងស្រែកមកយ៉ាងម៉េច?

ចាន់ផល ៈ  បាទ! មានសម្លេងស្រែកមកគេថាឲ្យស្ងៀមស្ងាត់ ហើយម្តាយខ្ញុំចេះតែខំយោលកូន យោលខ្ញុំនឹង គាត់ស្រែកថា អ្នកយាមនឹងស្រែកពីខាងក្រៅមកសំឡុតគាត់ ។

ដារ៉ា ៈ ៈ  អញ្ចឹងព្រឹកឡើងទេ ដែលគេបំបែកបងចេញពីម្តាយ?

ចាន់ផល ៈ  បាទ!

ដារ៉ា ៈ ៈ  ហើយបងទាំងប្អូនបង និងក្មេងម្នាក់ទៀតចេញពីបន្ទប់នឹងទៅ?

ចាន់ផល ៈ  បាទ!

ដារ៉ា ៈ ៈ  ហើយយកទៅខាងណាអី?

ចាន់ផល ៈ  បន្ទាប់មកទៀត ខ្ញុំនៅខាងក្រោយគុកជាមួយស្ត្រីវ័យពាក់កណ្តាលមនុស្សចាស់ ប្រហែលជាវ័យ៣០ ហើយគាត់នៅមើលថែពួកខ្ញុំនឹង គេបញ្ជាឲ្យមើលពួកខ្ញុំនឹង ថាមើលដាំបាយដាំឲ្យពួកខ្ញុំហូបនឹង ហើយព្រមទាំងក្មេងៗដទៃទៀត ប្រហែលជា៥-៦នាក់ទៀត នឹងប្រហែលជាក្មេងមកមុនខ្ញុំ ។

ដារ៉ា ៈ ៈ  អញ្ចឹងបន្ថែមទាំងបង៤នាក់ និងក្មេងម្នាក់ទៀត៥ បូកនឹងអ្នកដែលក្មេងពីមុនមកទៀតនឹងប្រហែលជាប៉ុន្មាននាក់?

ចាន់ផល ៈ  ប្រហែល៥-៦នាក់ ខ្ញុំអត់បានរាប់ទេ ប្រហែលខ្ទង់ប៉ុននឹង ។

ដារ៉ា ៈ ៈ  ហើយពីពេលនឹងបងបែកពីម្តាយបងរហូត?

ចាន់ផល ៈ  បាទ! បែករហូតដល់ពេលទឹកឡើងនឹង ពេលថ្ងៃត្រង់នឹង ម្តាយខ្ញុំបានឈរនៅលើអគារទីកនឹងគាត់សំឡឹងមកអគារខាងក្រោយបង្អួចបែរមកមើលពួកខ្ញុំ ដោយមានភាពក្រៀមក្រំ ហើយខ្ញុំក៏សំឡឹងមើលគាត់វិញដែរ ដោយមិនមានបោះពាក្យសម្តីឆ្លងឆ្លើយគ្នាទេ ។ ហើយក្រោយមកទៀត ស្អែកឡើងមកទៀត អត់ឃើញម្តាយខ្ញុំរហូតដល់ថ្ងៃបែក ថ្ងៃរំដោះ ។

ដារ៉ា ៈ ៈ  ចុះបងនៅក្នុងបរិវេណគុកនឹងរហូតម៉ង?

ចាន់ផល ៈ  ខ្ញុំនៅក្នុងនឹងដល់ច្រើនយូរច្រើនខែដែរ ខ្ញុំអត់បានចាំ ដល់វៀតណាមឲ្យចូលមក ។

ដារ៉ា ៈ ៈ  បងអត់បានចាំថាមានឆ្នាំណាទេ ដែលបងមកដល់ទួលស្លែងទេ?

ចាន់ផល : ខ្ញុំមិនបានចាំទេ ខ្ញុំចាំថាជារដូវមួយ ខ្ញុំដឹងថាជារដូវមួយអត់ដែលមានភ្លៀងសោះ ខ្ញុំតាំងពីមកពីចាប់យកមកជាមួយម្ដាយនឹង រហូតដល់គុកទួលស្លែងរហូតដល់រំដោះគឺអត់មានភ្លៀងម្ដងសោះ ខ្ញុំចាំបានថាប្រហែលជាខែប្រាំង ។

ដារ៉ា : : អត់មានភ្លៀងម្ដងសោះ តាំងពីថ្ងៃចាប់មកដល់ទួលស្លែង រហូតដល់វៀតណាមចូលមក?

ចាន់ផល : បាទ! អត់មានដែលមានភ្លៀងសោះ មិនដឹងខែប្រាំងខ្ញុំថាអត់មានអញ្ចឹង ។

ដារ៉ា : : ហើយជីវិតរបស់នៅទួលស្លែងយ៉ាងម៉េចដែរ បងអាចរៀបរាប់បានទេ ពីការហូបចុក ពីការធ្វើការងារ កាលដែលបងប្រទះឃើញទិដ្ឋភាពអីខ្លះនៅក្នុងទួលស្លែងនឹង?

ចាន់ផល : កាលនៅក្នុងនឹង ឃើញទិដ្ឋភាពដូចខ្ញុំថាឃើញសំរែក ស្រែកចេញពីខាងក្នុងបន្ទប់នឹង សម្រែកការឈឺចាប់ ឃើញធ្វើម៉េចស្រែកអ្ហួយៗ ។ ឃើញគេបណ្ដើរអ្នកទោសចេញពីអគារមួយទៅបន្ទប់មួយនឹងៗ ឃើញគេចងបិទភ្នែក ចងដៃទៅក្រោយហើយបិទភ្នែក ហើយស្លៀកតែខោខ្លីប្រធានមន្ទីរនឹង ដើររុញច្រានដើរខាងមុខអគារនឹង ទៅអគារមួយៗ ដូចទាល់តែមានអ្នកបណ្ដើរពីក្រោយបិទភ្នែក ។

ដារ៉ា : : ហើយភាគច្រើនពួកខ្មែរក្រហមធ្វើការនៅគុកនឹង មានវ័យប៉ុនណាប៉ុនណៃ ស្លៀកពាក់?

ចាន់ផល : ស្លៀកពាក់អាវដៃវែង ខោជើងវែង ហើយនឹងពាក់មួក ហើយមានកន្សែងបង់ក រុំកនឹង ហើយមានកាន់ដូចជាដំបង ខ្លះទៅ អត់ដូចអត់មានកាន់កាំភ្លើងទេ មានកាន់សោរ កាន់ឈ្មោះកាន់អី ឃើញតែប៉ុននឹង ។

ដារ៉ា : : ហើយបងដែលធ្លាប់ឮពួកខ្មែរក្រហមដែលធ្វើការនៅក្នុងគុកនឹងជជែកគ្នា?

ចាន់ផល : ឃើញជជែកគ្នាម្ដងម្កាល តែខ្ញុំអត់បាន អត់ហ៊ាននៅក្បែរដូចថាឃើញគេនៅខ្លាច យើងអត់ដែលហ៊ានទៅក្បែរទេ ខ្ញុំនៅខាងក្រោយជាប់ក្បែរអគារនឹង ។

ដារ៉ា : : កន្លែងនឹងជារោងកុមារ?

ចាន់ផល : បាទ! កន្លែងនឹងជារោងដាក់កុមារផង ជាកន្លែងរោងជាងដាំឈ្មោះ ដូចជាខ្ញុំចាំឈ្មោះតាគង់ៗ គាត់ជាជាងឈ្មោះ គាត់ដំ ពីមុនគាត់ជាជាងដំកាំបិត ដំចបនៅភូមិ ពេលក្រោយមកគាត់ចូលទៅក្នុងនឹង គេសួរគាត់ថាចេះដំឈ្មោះ ដំអី ដំកាំបិតចេះដំឈ្មោះ គាត់ថាអាចដំបាន ហើយបានគេឲ្យគាត់ធ្វើជាងឈ្មោះនឹងខាងក្រោយនឹង ។ បាទ! ពីមុនជាងចំលាក់ជាងអីនឹង សព្វថ្ងៃជាងចំលាក់រូបប៉ុលពត ។

ដារ៉ា : : គាត់ឈ្មោះអី ឈ្មោះតាគង់?

ចាន់ផល : ឈ្មោះតាគង់ ជាជាងឈ្មោះ ។

ដារ៉ា  : :   ចុះបងឃើញការផលិតឈ្មោះនៅក្នុងនឹង មាំទេ?

ចាន់ផល  :   បាទ! ខ្ញុំឃើញកំពុងដឹដែកដែលដុតក្រហមនឹង ដំពូងពាំង១គាត់ផាកមើលមកខ្ញុំ ហើយក្រោយមកថ្ងៃរំដោះនឹង បានខ្ញុំស្គាល់គាត់១ធ្វើការនៅមានស៊ីប្រាក់ខែឃួននៅក្នុងគុកនឹងទៀត អាដិនាន់បែកហើយនឹង ។

ដារ៉ា  : :   ឈ្មោះតាគង់?

ចាន់ផល  :   បាទ!

ដារ៉ា  : :   ដឹងថាឈ្មោះតាគង់ម៉ាត់ទេ?

ចាន់ផល  :   បាទ! ដឹងថាឈ្មោះអីទៀតទេ ប៉ុន្តែគាត់ធ្លាប់ធ្វើការនៅទីនោះ ប្រហែលជាមានបញ្ជីឈ្មោះគាត់នៅក្នុងបុគ្គលិកខាងឃួនបែកហើយនៅសារមន្ទីរទួលស្លែង ។

ដារ៉ា  : :   កាលដែលគង់គាត់ធ្វើជាជាងដាក់ឈ្មោះគាត់អាយុប្រហែលប៉ុន្មានបងស្មាន?

ចាន់ផល  :   ស្មានតាមមើល ប្រហែលជាអាយុជាង៦០ឆ្នាំ ៥៨ឆ្នាំ ។ រូបរៀងគាត់ម៉េចដែរ ស្គម-ស ស្គមមាឌស្ដើងរៀងខ្ពស់ ខ្ញុំឃើញមើលទៅរៀងសក់ស ខ្ទង់ប្រហែល៥០ជាង ។

ដារ៉ា  : :   បើសិនជាឃើញរូបថតអី បងចាំ?

ចាន់ផល  :   បាទ! បើឃើញរូបថតចាំ ។

ដារ៉ា  : :   ចាំឈ្មោះពូនឹង?

ចាន់ផល  :   បាទ! ចាំ ។

ដារ៉ា  : :   ហើយនៅក្នុងគុកទួលស្លែងនឹង បងធ្លាប់ទទួលការវ៉ៃ ឬក៏យ៉ាងម៉េចសំឡុត?

ចាន់ផល  :   បាទ! មានការសំឡុត រុញច្រាន ទាត់ធាក់នឹង វាមិនច្រើនណាស់ណា កាលណាយើងរត់ទៅរកក្បែរអ្នកទោសអីអញ្ចឹង យើងត្រូវបានគេសំឡុត គេចង្អុលរកវ៉ៃរកដំអញ្ចឹង យើងរត់មកវិញមក គេរកសំឡុតយើងរត់មកក្រុមកុមារវិញ ។

ដារ៉ា  : :   នៅក្នុងក្រុមកុមារបងមានបាត់សមាជិកទេ?

ចាន់ផល  :   កាលនោះ កាលពីវៀតណាមចូលមកនឹង ជិតបែកហើយ ដល់ពេលជិតបែកនឹង ដូចថាគេរកប្រមូលអ្នកទោស មើលតាមខ្ញុំដឹងឃើញគេប្រមូលក្មេង១ឡើងឡាន១ទៅ ដោយមានស្ត្រីចំណាស់នឹង បបួលខ្ញុំប្អូន១ឡើងឡានដែរ ហើយខ្ញុំអត់ឡើង ហើយខ្ញុំនឹងអត់ទាន់ឡើង ហើយខ្ញុំប្រមូលប្អូន១ខ្ញុំដាក់នៅក្នុងខោអាវអ្នកទោសដែលគេគរបោលខាងក្រោយនឹងគ្របទៅ ។ ហើយក៏ហៅខ្ញុំទៅ ខ្ញុំអត់ព្រមទៅដោយសារខ្ញុំនឹកឃើញថា គេថាកាលណាខ្ញុំចេញពីកន្លែងនឹង គឺម៉ែខ្ញុំគាត់រកខ្ញុំអត់ឃើញ ។ កាលខ្ញុំនៅនឹងម្ដាយខ្ញុំរកអត់ឃើញ

អត់ទាន់ទៅណាទេ ដល់ព្រូសម្ទេងគ្រាប់ប្លោងមកយូរៗម្តងៗ ឃើញគ្រាប់ប្លោងចុះមកនាំប្អូនគេចទៅ ។

ដារ៉ា : : ចុះកាលពីនៅក្នុងកន្លែងកងកុមារមើលថែរក្សា មើលកុមារនៅទួលស្វែងនឹង កំឡុងពេលនឹង បងមាននឹកនាម្ដាយសួរនាំអ្នកមើលថែទាំបងថាម្ដាយបងយ៉ាងម៉េចៗ?

ចាន់ផល : បាទ! ខ្ញុំអត់ហ៊ានសួរទេ មានការគំរាមកំហែងសំឡុតពីខាងមុខខាងក្រោយនឹង ខ្ញុំអត់ហ៊ានសួរទេ ស្ត្រីនោះសួរទៅវិញគាត់ពេលដែលចូលមកនឹងដែលប្រមូលអ្នកទោសឡើងឡាននឹង ខ្ញុំអត់ឡើងឡានខ្ញុំអត់ព្រមខ្ញុំទៅប្រមូលខោអាវមក ហើយដល់ពេលនេះទៅខ្ញុំម៉េចហ៊ានចូលរត់មករកខោអាវខ្ញុំទៀត ខ្ញុំចូលពួនផុតហើយ គេរកអត់ឃើញ រក២ដង ដើរ៤បកទៅមកៗមើលឆ្វេងស្តាំអត់ឃើញខ្ញុំ វាសុខចិត្តព្រមបើកឡានដឹកអ្នកទោសចេញទៅ ។ ដល់ចេញទៅ កាលនោះខ្ញុំព្រូគ្រាប់កាំភ្លើងខ្លាំងណាស់ ប្លោងចូលមក ខ្ញុំរត់ទៅក្រោយ ។ ទៅក្រោយមក ខ្ញុំរត់ប្រហែល២ខ្ញុំរត់ក្នុងគុក ខ្ញុំរកម្ដាយខ្ញុំ ស្រែករកម្ដាយខ្ញុំទៅតាមបន្ទប់នឹងក៏បើកចំហរ មានបន្ទប់ខ្លះអត់បើកចំហរទេ ចេះតែអើតមើលមិនឃើញមានមនុស្សទេ ឃើញតែសាកសពនៅលើគ្រែដែលជាប់ឃ្នោះនឹង ឃើញខ្មោចឃើញគេអាករៗថ្មីៗនៅសម្លាប់ហើយថ្មីៗនឹង គ្មានរុយរុំទេ ប៉ុន្តែនៅលើខ្មោច នៅលើសាកសពនឹងអត់ទាន់ហើមនៅឡើង ទើបនៅថ្មីៗ ឈាមស្រស់ៗប្រហែលជាជាប់ប្រហែលជា២ទៅ៣នៅឡើយ ។ ក្រោយពីឡានដឹកអ្នកទោស ដែលចេញទៅកុមារ២នាក់ប៉ុន្មាននាក់ឡើងទៅ ។

ដារ៉ា : : អញ្ចឹងបងពួកទាំង បងប្អូនបងទាំង?

ចាន់ផល : ៤នាក់ ។

ដារ៉ា : : ទាំង៤ពួកនៅក្នុងគំនរខោអាវនឹង?

ចាន់ផល : បាទ!

ដារ៉ា : : គំនរខោអាវធំ បាន?

ចាន់ផល : គំនរខោអាវធំដែរ ដូចជាពំនូតចំប៉ើងមន្ទអាគមន៍ ហើយអ្នកទោសរាប់រយនាក់ រាប់ពាន់នាក់ខោអាវវាត្រូវបានចូលមក គឺគេត្រូវដោះខោអាវចេញ ហើយជាខោអាវខ្ទីនេះជាខោអាវអ្នកទោស ជួនកាលខ្ញុំស្លៀកខោអាវអ្នកទោសខ្លះដែរ ។

ដារ៉ា : : ចុះពេលដែលបងរត់ពីឡានពេលខ្មែរក្រហមដឹក ដូចថាក្មេងៗដែលរត់ចេញអស់ហើយ បងរត់ស្រែករកម្ដាយនឹង នៅក្នុងពេលនឹងដូចថាអត់មានមនុស្សសោះ?

ចាន់ផល : បាទ! អត់មានមនុស្សសោះ មានតែគ្រាប់ប្លោងចូលកាន់តែខ្លាំងឡើងៗទៅហើយ ។

ដារ៉ា ៖ ទាំងប្អូនបងរត់ប្រសេចប្រសាចពេលនឹង?

ចាន់ផល ៖ បាទ! ពេលនឹងអត់មានទៅណាទេ នៅម៉ាកន្លែងពេលគ្រាប់ធ្លាក់ខ្លាំងទេ មានតែខ្ញុំទេរត់រកម្ដាយ ស្រែករកម្ដាយតាមបន្ទប់ ជួនកាលមានបន្ទប់ខ្លះបិទទ្វារជិត ខ្ញុំចាក់សោរមានបន្ទប់ខ្លះមិនមានសោរ ។ ស្វែងរក ប៉ុន្តែជំនាន់នោះ យើងមានចេះម៉ាក់ប៉ាអី យើងស្រែកហៅម៉ែៗ ស្រែករកម៉ែៗបើសិនជាម្ដាយខ្ញុំនៅមែន គាត់ឮសម្លេងខ្ញុំ គាត់ស្គាល់សម្លេងហើយ ។

ដារ៉ា ៖ ចុះបងបានរត់មកបន្ទប់ដែលម្ដាយបងគាត់ដាក់ថ្ងៃមុនដំបូង?

ចាន់ផល ៖ បាទ! ឡើងមកបន្ទប់នឹង ឃើញចាក់សោរ អត់ឃើញម្ដាយខ្ញុំទេ ។

ដារ៉ា ៖ គេចាក់សោរ ឬបើកសោរ បើកទ្វារ?

ចាន់ផល ៖ បន្ទប់នឹងចាក់សោរ ប៉ុន្តែខ្ញុំមើលតាមបង្អួចទៅចំហរដូចអត់មានឃើញ អត់មានឃើញ ។

ដារ៉ា ៖ អត់មានមនុស្សសោះ?

ចាន់ផល ៖ បាទ! អត់មានឃើញម្ដាយ អ្នកណាម្នាក់អត់មានទេ ។

ដារ៉ា ៖ បងដើររកប្រហែលជាប៉ុន្មានបន្ទប់ទៅ?

ចាន់ផល ៖ ខ្ញុំរត់ទៅមិនបានសព្វទេ ប៉ុន្តែដូចបានតែអគារកណ្ដាលយើងមួយ ហើយនឹងអគារខាងទី១ អគារអេ អគារប៊ី អគារក អគារខ ខ្ញុំរត់ខាងមុខអគារ បាន៤-៥ជំហានខ្ញុំស្រែកម្ដងៗ ដល់ពេលអត់ឮខ្ញុំរត់មករកប្អូនខ្ញុំវិញ ។

ដារ៉ា ៖ ពេលរត់នឹង មានជួបសភាពអីដូចបងដែលឃើញសពនៅនឹងច្រើនទេ?

ចាន់ផល ៖ ឃើញសព្វនៅនឹងក្រែដែរ នៅក្នុងរូបថតមានរាល់ថ្ងៃឃើញសាកសព៣-៤សាកសពៗសុទ្ធតែមនុស្ស ។

ដារ៉ា ៖ ពូរស់នៅកន្លែងកុមារម៉ារយៈពេលនឹង ពូអត់ដែលឮគេហៅ អត់ដែលឮខ្មែរក្រហមផ្សេងទៀតគេហៅមីងម្នាក់ដែលមើលការខុសត្រូវកុមារនឹងទេ?

ចាន់ផល ៖ អត់មានឃើញហៅ ប៉ុន ។

ដារ៉ា ៖ បងអាចស្គាល់ឈ្មោះគាត់ទេ?

ចាន់ផល ៖ អត់បានស្គាល់ឈ្មោះគាត់ផង អត់ដឹង អត់ហ៊ានសួរគាត់ផង ។

ដារ៉ា ៖ បានខ្ញុំសួរថាដែរឮខ្មែរក្រហមហៅមីងនឹងថាឈ្មោះចេះ ឈ្មោះចុះ ម៉ារយៈពេលបងនៅកន្លែងកុមារ?

ចាន់ផល ៖ អត់ អត់បានឮ ។

ដារ៉ា ៖ គាត់រៀនរៅយ៉ាងម៉េចដែរ?

ចាន់ផល ៖ គាត់រៀងសខ្ពស់ស្រឡះ ហើយស្លៀកពាក់ពណ៌ខ្មៅ ។

ដារ៉ា ៖ នៅក្នុងទួលស្លែងនឹង បងមានធ្លាប់ឮហៅជាឈ្មោះ អ្នកណាហៅថាឈ្មោះ បងមានធ្លាប់ឮហៅឈ្មោះ បងមានធ្លាប់ឮអញ្ចឹង?

ចាន់ផល ៖ ខ្ញុំធ្លាប់ឮសំរែកស្រែកទៅយោសទៅមកៗ ប៉ុន្តែខ្ញុំអត់បានចាំ ជួនកាលអ្នកយាមគុកស្រែកទៅមកៗដែរ ឮសំរែកហៅគ្នាទៅមក ។

ដារ៉ា ៖ តែអត់ឮជាស្រែកជាឈ្មោះជាអី?

ចាន់ផល ៖ បាទ! ជាឈ្មោះដូចជាការស្រែកសួរគ្នាទៅវិញទៅមក ។

ដារ៉ា ៖ នៅក្នុងបរិវេណទួលស្លែងនឹង បងអាចប៉ាន់ស្មានមើល ទំហំប៉ុនណាដែរ ដែលបងអាចដើរជុំវិញបាន?

ចាន់ផល ៖ ទំហំ កាលខ្ញុំនៅតូច ខ្ញុំគិតថាវាទំហំធំណាស់ តែរហូតមកដល់ពេលនេះ បានខ្ញុំដឹងថាវាមិនធំប៉ុន្មាន គឺថាខ្ញុំរត់ចុះរត់ឡើងវាសឹងតែវង្វេងដែរកាលខ្ញុំនៅតូច ហើយវាមិនមានភាពស្រឡះដូចអញ្ចឹង ដូចរៀងស៊ីបទ្រុប ។ ដល់ឥឡូវដល់គេធ្វើសួនធ្វើអីទៅ មើលលែងចង់ស្គាល់ខាងក្នុង ។

ដារ៉ា ៖ ពេលបងស្រែករកម្តាយអត់ឃើញ បងវិលត្រឡប់ទៅរកបងខាងនៅក្នុងរោងអាវ?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ពេលនឹងវៀតណាមទៅដល់ម៉េចអីជួបគ្នាម៉េច?

ចាន់ផល ៖ វៀតណាមចូលទៅដល់គាត់សួរខ្ញុំ ហើយខ្ញុំសឹងតែរត់ពួនហើយ គ្រាន់គាត់មកវ៉ាក់អើជួបអត់ដឹងខ្លួន ។

ដារ៉ា ៖ ជួបកន្លែងណា?

ចាន់ផល ៖ ជួបនៅខាងក្រោយកន្លែងដាំងធ្វើឈ្មោះ ខាងក្រោយរោងដាំងនឹង ខ្ញុំចូលៗទៅវ៉ាក់អើៗទៅគាត់ឃើញ ខ្ញុំគ្មានស្លៀកពាក់វៀតណាមអីដូចខ្ញុំ ធម្មតាស្លៀកពាក់ធម្មតាមានកាន់កាំភ្លើងម្នាក់មួយដើម ។

ដារ៉ា ៖ ហើយមានគ្នាប៉ុន្មាននាក់ពេលបងជួប?

ចាន់ផល ៖ គ្នា២នាក់ ម្នាក់និយាយខ្មែរ ម្នាក់ទៀតអត់និយាយ បានសួរខ្ញុំថា ខ្ញុំកូនប៉ុលពត? ខ្ញុំថា ខ្ញុំអត់ទេ ខ្ញុំមិនមែនកូនប៉ុលពតទេ ខ្ញុំអត់ស្គាល់ទេ ។ ហើយអញ្ចឹងក្មួយឯងកូនអ្នកណា ខ្ញុំថាខ្ញុំមានឪពុកម្តាយផ្សេង ខ្ញុំកូនតាជិន យាយយើល ម្តាយខ្ញុំឈ្មោះជិន ហើយឪពុកខ្ញុំ

ឈ្មោះយោល ប៉ុនខ្ញុំឆ្លើយអញ្ចឹង បានជាគាត់សួរខ្ញុំថា ហេតុអីបានជាមកទីនេះ? ថាគេយកម្ដាយខ្ញុំមកទីនេះ ខ្ញុំមកជាមួយម្ដាយខ្ញុំ។ ហើយកាលនោះខ្ញុំមិនដឹងកន្លែងនេះ ជាកន្លែងអីផង ទើបដឹងឥឡូវនេះទេ។

ដាវ៉ា : : ហើយបន្ទាប់មក ចូលតែពីរនាក់អញ្ចឹង មានជាការថេតកាំម៉ារ៉ា មានថតមានអីទេ ពេលដែលពីរនាក់នឹងមក?

ចាន់ដល : បាទ! អត់ទាន់មានថតទេ ទាល់តែពេលស្អែកឡើងយប់ប្រហែល ល្ងាចប្រហែលម៉ោង៦ ម៉ោង៥ ៦ ៧មិនដល់ម៉ោង៧ពេក ប៉ុន្តែមានទ័ពវៀតណាមមក។

ដាវ៉ា : : ពេលដែលចូលមកដល់មុនដំបូងនេះ ចូលមកទួលស្លែងនឹងបងគិតថាទាហានវៀតណាមដែលថា២នាក់ស្ពាយកាំភ្លើងនឹង ចូលមកដល់ម៉ោងប្រហែលម៉ោងប៉ុន្មាន?

ចាន់ដល : ប្រហែលម៉ោង៣ ម៉ោង៤រសៀល។

ដាវ៉ា : : ម៉ោង៣ ម៉ោង៤រសៀល?

ចាន់ដល : បាទ!

ដាវ៉ា : : ពេលជួបហើយ សួរនាំហើយ គេនាំអ្នក២នាក់នឹងនាំបងទៅជួបប្អូនខាងក្រោយប្រយ៉ាងម៉េច រៀបរាប់មើល?

ចាន់ដល : ពេលដែលខ្ញុំរៀបចូលពួននៅក្នុងគំនរខោអាវនឹង ដូចថាខ្ញុំស្ងាត់ហើយ ខ្ញុំអត់ចង់ចូលពួននៅខាងក្នុង ដូចថាវាហប់ពេក ដល់ពេលនឹងវាវាក់អើជាមួយទាហាន ២នាក់នឹង ទាហានដូចស្លៀកពាក់ដូចជាមនុស្សធម្មតា ប៉ុន្តែមានកាំភ្លើង។ វ៉ាក់អើ! មានការភ័យខ្លាចដែរដែលគាត់សួរអញ្ចឹង ឆ្លើយដូចខ្ញុំជម្រាបបងមិញ។

ដាវ៉ា : : ដល់ក្រោយមក បងនាំគាត់ទៅកន្លែងប្អូនបង ប្រដើរទៅណា?

ចាន់ដល : គាត់មកមើលឃើញនៅកន្លែងពួននឹង ឃើញបងប្អូន៤-៥នាក់នឹង កូនក្មេងដែលមកជាមួយស្រីចំណាស់២នាក់នឹងវាចាប់ផ្ដើមឈឺហើយ ឈឺអត់មានអាហារផង។

ដាវ៉ា : : ក្មេងនឹងនៅរស់នៅពេលដែលខ្មែរក្រហមរត់ទៅបាត់ហើយ នៅរស់ដែរ?

ចាន់ដល : នៅរស់ដែរ ប៉ុន្តែដូចបាត់មាត់ បាត់កវាដូចចេះតែដេក។ទៅរហូត លែងមានចលនាហើយ ប៉ុន្តែខ្ញុំដឹងថានៅរស់ ដោយសារនៅដកដង្ហើម។ អញ្ចឹងដល់ក្រោយមក ពេលល្ងាចថ្ងៃស្អែកមកឡើង បានកូននឹងវាចង់ផុតទៅហើយ វាលែងកំរើកដៃ កំរើកជើង កំរើកពោះ។

ដារ៉ា ៈ ៈ ពេលដែលបងនាំមនុស្ស២នាក់ពេលឃើញមកដល់ទួលស្លែងមុនដំបូង ហើយទៅជួបជាមួយបង វាប្រហែលជាដល់ម៉ោង៥-៦នឹង ក្នុងថ្ងៃនឹង ពេលរសៀលនឹង ពេលជួបហើយនាំទៅណាៗទៀត ឬក៏បងមានឃើញទិដ្ឋភាពអីទៀត?

ចាន់ដល ៈ ក្រោយពេលនាំហើយ ទាហាន២នាក់នឹង អត់មាននាំអីទេ គ្រាន់តែចូលមកគាត់ហាក់បីដូចជាគាត់ដឹងពុ គាត់ដឹងបរិវេណគុក គឺថាកន្លែងនេះមានអីៗហើយ គ្រាន់ហើយបានគាត់បកចេញទៅវិញទៅ ចេញទៅបាត់ម៉ាភ្លេត ។

ដារ៉ា ៈ ៈ ពេលចេញទៅអត់បានជួយបងអីយ៉ាងម៉េចៗ?

ចាន់ដល ៈ គាត់ជួយដែរ គាត់ជួយដាំបាយឲ្យហូបនឹង ប៉ុនមិនដឹងអង្ករនឹងគាត់បានមកពីណាទេ គាត់ដាក់ជាប់ខ្លួនមក ។ គាត់ដាំបាយឲ្យខ្ញុំម៉ាឆ្នាំង រៃទាមួយ នៅក្នុងគុកនឹងមានទាមួយ គាត់រៃទាមួយស្ងោរឲ្យពួកខ្ញុំហូបហើយ គាត់ក៏ចេញបាត់ទៅ ។

ដារ៉ា ៈ ៈ នៅថ្ងៃនឹងបង និងជាមួយប្អូនបងប៉ុន្មាននាក់ ហើយនឹងក្មេងម្នាក់ទៀតដែលថានៅសល់នឹងនៅក្នុងគុកនឹងនៅឡើយទេ អត់ទាន់ចេញទៅណា ទៅជាមួយមនុស្ស២នាក់?

ចាន់ដល ៈ បាទ! អត់ទាន់ចេញទៅទេ ។

ដារ៉ា ៈ ៈ នៅក្នុងគុកនឹងឯង?

ចាន់ដល ៈ បាទ!

ដារ៉ា ៈ ៈ គេងនៅក្នុងគុកនឹង នៅក្នុងគំនរខោអាវនឹង?

ចាន់ដល ៈ បាទ! គេងនៅក្នុងនឹងម៉ាយប់ បានស្អែក បានយកខោអាវពីយប់ម៉ោង៦ៗបានឃើញទ័ពវៀតណាមចូលទៅច្រើនម្តងទៀត ឃើញស្លៀកពាក់ទាហានវៀតណាម ហើយនឹងកងទ័ពរណសិរ្ស មិនមាន មិនដឹងកងទ័ពរណសិរ្ស មិនដឹងអ្នកណាទេ លាយចំរុះគ្នាមានអ្នកចេះនិយាយខ្មែរ មានអ្នកចេះនិយាយវៀតណាម ។

ដារ៉ា ៈ ៈ រំលងមួយយប់ដែលបងគេងហើយ បានភ្ញាក់ឡើងហើយមកបានមានទាហានទាំងហ្វូងទាំងហ្វូងហ្វាយចូលទៅ?

ចាន់ដល ៈ បាទ! ចូលទាំងហ្វូងទាំងហ្វូង បានប្រមូលពួកខ្ញុំមកនឹង ប្រមូលពួកខ្ញុំឡើងឡានមកចេញពីគុកនឹង ។

ដារ៉ា ៈ ៈ ហើយពេលនាំទាំងហ្វូងទាំងហ្វូង បាននាំបងឡើងឡានអីចេញទៅ?

ចាន់ដល ៈ បាទ!

ដារ៉ា ៈ ៈ អញ្ចឹងបងជួយរៀបរាប់បន្តិចមើល ពេលដែលទាហានមកច្រើនចូលទួលស្លែង ហើយជូនបងឡើងឡានទឹង ហើយឡើងឡានយ៉ាងម៉េចអីយ៉ាងម៉េចទៅណា?

ចាន់ផល ៈ ឡើងឡាន បើតាមខ្ញុំនៅចាំ ឡើងឡានទឹងជិះឡានយូរដែរ ខ្ញុំនៅចាំជិះមកដល់ថា ខ្ញុំនៅចាំបានថាបច្ចុប្បន្នខ្ញុំស្គាល់កន្លែងនឹងថាពេទ្យសម្តេចក្រុងយើង បៀតប៉ុស្តិ៍លេខ៩រាល់ថ្ងៃបុរីកីឡានោះ យកទៅដាក់នៅនឹង ហើយប្អូនខ្ញុំត្រូវបានគេចាក់ថ្នាំសង្គ្រោះ ត្រូវបានព្យួរសារ៉ូម បន្តក់ទឹកឲ្យ ព្រោះវាអត់អាហារប៉ុន្មានថ្ងៃនឹងចុងក្រោយនឹង ដាច់ឈឹងដាច់ខ្យល់ហើយ ប្អូនខ្ញុំអាពៅនឹង។ ហើយប្អូនស្រីមួយទៀត ត្រូវបានកង់ទ័ពវៀតណាមព្យួរសារ៉ូមឲ្យ ចំណែកខ្ញុំ២នាក់ប្អូនប្រុសមួយទៀត គេងនៅវាអាចដើរបាន អង្គុយបាន ក្រៅពីគេមានអាហារឲ្យហូបនឹងហើយ ។

ដារ៉ា ៈ ៈ ចុះក្មេងមួយតូចដែលថាម្តាយពីរនាក់ដែលគេយកមកដែរ?

ចាន់ផល ៈ បាទ! កូននោះស្លាប់ហើយ ត្រូវបានកងទ័ពដែលគេចូលទៅក្រោយច្រើនគ្នានឹង បានជួយកប់នៅខាងក្រោយទួលស្លែងនឹងហើយ គ្នាដាច់ខ្យល់ស្លាប់ហើយ ។

ដារ៉ា ៈ ៈ ចុះពេលដែលទាហាន២នាក់ចូលទៅជួបបងមុនដំបូង ហើយដាំ ដាំអីឲ្យហូប ផ្ញើទា ក្មេងម្នាក់នឹងអាចញ៉ាំអីបានទេ?

ចាន់ផល ៈ ញ៉ាំលែងបានហើយ បញ្ចុកដែរ ប៉ុនបញ្ចុកនៅវាហូបអត់កើត ចុះគ្នានៅក្មេងពេក អាយុប្រហែលម៉ាខួប ក្មេងបីនៅនឹងដៃ បាទ! លែងញ៉ាំកើតហើយ ។

ដារ៉ា ៈ ៈ ហេតុអីបានមកតាមបងកើត បងយកមកលាក់ក្មេងជាមួយគ្នា?

ចាន់ផល ៈ បាទ! ប្រមូលលាក់ជាមួយគ្នា ព្រោះខ្ញុំដឹងថាក្មេងដែរ ម្នាក់នឹងត្រូវមកជាមួយម្តាយខ្ញុំត្រូវប្រមូលទៅពួននៅក្នុងគំនរខោអាវនឹង ។

ដារ៉ា ៈ ៈ រាល់ថ្ងៃនឹងបងប្អូនបងដែលដូចថានៅកន្លែងគុកទួលស្លែងទាំងអស់គ្នា នៅរស់នៅបានប៉ុន្មាន?

ចាន់ផល ៈ នៅបច្ចុប្បន្ននៅបាននៅសល់៤នាក់ ។

ដារ៉ា ៈ ៈ ប្អូនមួយណាដែលបងថាស្លាប់?

ចាន់ផល ៈ អត់ស្លាប់ទេ ប្អូននឹងត្រូវបាន ក្រោយមកបញ្ជូនឲ្យទៅនៅកុមារកំព្រានៅជិតសង្គ្រោះទារកយើងនេះ នៅជិតពេទ្យកាល់ម៉ែត្រយើងនេះ ហើយក្រោយមកមានប្រជាជនខាងក្រៅសុំជាកូនចិញ្ចឹមទៅ ហើយចាំបាច់ ដូចអត់បានចាំអត់បានដឹង ដូចថាពួកខ្ញុំនៅតូចៗពេកត្រូវបានអ្នកគ្រូ លោកគ្រូអ្នកគ្រូនៅថែទាំទាំងអស់នោះបានគេឲ្យទៅអ្នកប្រជាជននៅខាង

ក្រៅសុំទទួលជាកូនចិញ្ចឹម ។ ហើយថានៅម្តុំស៊ឹងមានជ័យយើងនេះ ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណាអ្នកណែ ទៅរកសួរដែរ ប៉ុន្តែនៅក្មេងពេកវាអត់បានចាប់អារម្មណ៍ ខ្ញុំអត់ចេះត្រង់នឹងដឹងបាត់រហូតនៅបច្ចុប្បន្ន ។ ហើយប្អូនស្រីខ្ញុំមួយទៀត ត្រូវបានសង្គ្រោះពីវៀតណាមយកមកគុកទួលស្លែង មានដំណឹងថាគេយកសុំយកទៅពីកន្លែងកុមារកំព្រាដែរ ថាគេទទួលជាកូនចិញ្ចឹមថានៅប្រទេសអាឡឺម៉ង់ ។ ប៉ុន្តែការពិតខ្ញុំអត់ដឹងច្បាស់ ថាមានអ្នកកាសែតមួយ មកសម្ភាសន៍ខ្ញុំដែរ គាត់ប្រាប់ ។

ដារ៉ា : : គាត់ប្រាប់ថាម៉េច?

ចាន់ផល : គាត់ថាចង់ជួបប្អូនទេ? ខ្ញុំថាចង់ជួប តើប្អូនខ្ញុំនៅឯណា? ត្រូវបានគេទទួលចិញ្ចឹមសុំជាកូនចិញ្ចឹមនៅប្រទេសអាឡឺម៉ង់ ។ ប៉ុន្តែអត់ដឹងថា ពិតឬមិនពិតទេ អត់ដឹងទេ គ្រាន់តែឮគាត់ថាអញ្ចឹងក្រោយមក បាត់រយៈដំណឹងឈឹងទៅ ។

ដារ៉ា : : ប្រហែលជាប៉ុន្មានឆ្នាំ បានបងបានជួបអ្នកកាសែតសួរនាំចង់ស្គាល់ប្អូន ប្អូននៅអាឡឺម៉ង់អីនឹង?

ចាន់ផល : បាទ! តាំងពីឆ្នាំ៧៩មកដល់ចុងឆ្នាំ ប្រហែលចុងឆ្នាំ៩២, ៩១, ៩២បានខ្ញុំដឹងថាប្អូននឹងបាននៅអាឡឺម៉ង់ ៩១, ៩២ពេលអ៊ុកគាក់ចូលហើយ ចូលមកបណ្តើរៗហើយ ។

ដារ៉ា : : ច្បាស់ហើយថាអ្នកកាសែតនឹងស្គាល់បង និងស្គាល់ប្អូនបង ហើយប្រាប់ថានៅនឹង?

ចាន់ផល : បាទ! អ្នកកាសែតនឹងមក ជនជាតិជប៉ុននឹងមក គេមកជាមួយជនជាតិអាឡឺម៉ង់ បងនឹងខ្ញុំនៅចាំបាន គាត់ថាគាត់នឹងមកពីទូរទស្សន៍ជាតិ ទូរទស្សន៍ទទកបច្ចុប្បន្ននឹង គាត់នាំអ្នកកាសែតជប៉ុននឹងមកជួបខ្ញុំនឹង ។ ក្រោយមកបាត់ដំណឹងឈឹងរហូត គាត់មិនបានឲ្យនាមប័ណ្ណបញ្ជាក់ណា គាត់ប្រាប់ថាគាត់ធ្វើការនៅទូរទស្សន៍ជាតិ ។

ដារ៉ា : : គាត់មានរូបរៀងម៉េចដែរ ខ្មែរយើងដែរនៅ?

ចាន់ផល : គាត់មុខស្អាតជាងនឹង គាត់មានរាងខ្ពស់ សម្បុរសណ្តែកបាយយើងនឹង ហើយខ្មៅមិនខ្មៅសមិនស ខ្ពស់ មានរាងដំបងខ្ពស់ មុខមាត់គាត់ដូចជាមិនសូវបានចាំដែរ ។

ដារ៉ា : : ហើយតាំងពីពេលនឹង បងអត់ដែរតាមរកបងដែលនៅទូរទស្សន៍ជាតិនឹង សួរពីព័ត៌មានប្អូនស្រីរបស់បងដែលទៅអាឡឺម៉ង់នោះទេ?

ចាន់ផល : បាទ! អត់បានសួរគាត់ ខ្ញុំអត់មានអត់ដឹងទាក់ទងខាងណាដើម្បីទៅជួបគាត់ អត់ស្គាល់កន្លែងផង រហូតម៉ារយៈបាត់ដំណឹងរហូតដល់បច្ចុប្បន្ននោះ ។

ដារ៉ា ៖ ចុះមួយទៀតដែលថាប្អូនប្រុសដែលថាមានប្រជាជនដែលសុំយកទៅចិញ្ចឹមបន្ត បងដែលមានមកតាមរក តាមអីដែរ?

ចាន់ផល ៖ តាមរក គ្រាន់តែសួរអ្នកគ្រូ លោកគ្រូនៅកន្លែងកុមារកំព្រា នៅកន្លែងសង្គ្រោះក្មេងកំព្រាទារកនឹង ទៅដល់នឹងមិនដឹងសួរពីណាទៅណាដង ចេះតែស្ងប់ស្ងាត់ទាល់ឥឡូវ ។ យកទៅមិនដឹងថាអ្នកយកទៅឈ្មោះអីៗ អត់បានដឹង ទៅសួរខាងសង្គ្រោះទារកក៏គេអត់មានក្រដាសស្នាមថាបញ្ជាក់ថាក្មេងនោះត្រូវបានអ្នកណាផ្ញើអី ទទួលយកទៅចិញ្ចឹមអត់ អត់មានរហូតដល់បច្ចុប្បន្ននេះ មិនដឹងមុខម៉េច មិនដឹងជារស់ឬស្លាប់ ។

ដារ៉ា ៖ ប្អូនកាលនឹងអាយុប៉ុន្មាន អាពេលរំដោះហើយ?

ចាន់ផល ៖ រំដោះហើយ អាយុប្រហែលម៉ាខួបកន្លះ វានៅអ៊ឹមនៅឡើយ ។

ដារ៉ា ៖ ឈ្មោះអីទៅ ដែលថាប្រជាជនយកទៅចិញ្ចឹម?

ចាន់ផល ៖ បែកហើយនឹង អត់មានឈ្មោះទេ ក្រោយមកវៀតណាមជួយសង្គ្រោះបានរស់នឹងវៀតណាមរំដោះបានខែមករា ដាក់ឈ្មោះវាថាភាសាវៀតណាមដាក់ឈ្មោះថា ឡាថាំង ។

ដារ៉ា ៖ ឈ្មោះអី?

ចាន់ផល ៖ ឡា ថាំង បាទ! ភាសាខ្មែរយើងហៅថាខែមករា ដាក់ឈ្មោះថាមករានឹងទៅ នឹងវាអត់ទាន់មានឈ្មោះទេ កងទ័ពវៀតណាម កងទ័ពរណសិរ្សដាក់ឲ្យ ។

ដារ៉ា ៖ ហើយចុះប្អូនស្រីពុំដឹងណឹងថានៅអាឡឺម៉ង់ឈ្មោះអី?

ចាន់ផល ៖ ឈ្មោះរបស់វាឈ្មោះ សុជាតិ ។

ដារ៉ា ៖ ឈ្មោះសុជាតិ?

ចាន់ផល ៖ បាទ! ឈ្មោះសុជាតិ ហៅក្រៅ យើងមកនៅមណ្ឌលកុមារកំព្រាហើយ បានអ្នកគ្រូលោកគ្រូនឹងដាក់ឈ្មោះជាតិរំដួល ខស្សាហ៍សួរវាទៅ ខ្ញុំមិនបាននៅក្បែរដាក់ចំណែកដាក់ចំណែកជាតិ ដល់ពេលគេអត់បានសួរខ្ញុំដល់ពេលលោកគ្រូអ្នកគ្រូចេះតែដាក់ឲ្យទៅ នៅក្នុងកុមារកំព្រាមានច្រើនណាស់ សុទ្ធតែអ្នកអត់ដែលស្គាល់ឈ្មោះឯង ហើយត្រូវបានលោកគ្រូអ្នកគ្រូដាក់ឈ្មោះឲ្យ ដូចពៅឈ្មោះអីដែលបានថតឡើងនោះ ក៏សុទ្ធតែអ្នកអត់មានឈ្មោះ ហើយដែលត្រូវលោកគ្រូអ្នកគ្រូដែលនៅថែរក្សាកុមារកំព្រានឹងដាក់ឲ្យទៅ ។

ដារ៉ា ៖ ចុះបងនៅពេលនឹង បងមានឈ្មោះអីដែរ?

ចាន់ផល ៖ កាលពីជំនាន់អាពតនឹងគេហៅកុមារឡានៗ ។

ដារ៉ា ៖ កុមារឡាន?

ចាន់ផល ៖ បាទ! ដល់ពេលបច្ចុប្បន្នមក ឈ្មោះនឹងត្រូវបានគេបន្ទប់ថាឈ្មោះឡានម៉េច ឈ្មោះមើលដែកឈ្មោះមើលម៉ាស៊ីនអញ្ចឹង បានដូរដាក់ឈ្មោះផលវិញ ។

ដារ៉ា ៖ កាលពីវៀតណាមរំដោះថ្មីៗ ដែលវៀតណាមយកមកចិញ្ចឹមនៅសាលា បងដាក់ឈ្មោះម៉េច ដាក់ឈ្មោះផលនឹងដែរ ។

ចាន់ផល ៖ ចុះប្អូនមួយទៀតនោះ បាន៣ទាំងបងដែរ?

ដារ៉ា ៖ ប្អូនខ្ញុំមួយទៀត ដោយសារវាកើតពីអាពតនឹងវាខ្មៅ ដល់ហើយដាក់ឈ្មោះពិនិត្យៗ ដល់ក្រោយមកគេហៅអាណិត ។ ឈ្មោះអាណិត ។

ចាន់ផល ៖ ឈ្មោះណិតនឹងនៅទេ?

ដារ៉ា ៖ បាទ!នៅរាល់ថ្ងៃ ។

ចាន់ផល ៖ បាទ! នៅគេមានគ្រួសារ គេទៅរស់នៅបែកធម្មតាដូចប្រជាជនទូទៅហើយ ។

ដារ៉ា ៖ អញ្ចឹងបងបាត់ដំណឹងតែ២ទេ?

ចាន់ផល ៖ បាទ! បាត់ដំណឹងប្អូន២ ។

ដារ៉ា ៖ ខាងមករា ហើយនឹងមួយទៀតឈ្មោះ ជាតិ ឬរំដួល?

ចាន់ផល ៖ បាទ!

ដារ៉ា ៖ ដូចថាបងចង់ស្វះស្វែងរកប្អូនបងដែរ ឬយ៉ាងម៉េច?

ចាន់ផល ៖ បាទ! ខ្ញុំចង់ស្វះស្វែង ក្រោយមកខ្ញុំបានដាក់នៅក្នុងអង្គការមួយនោះ គេរក បាទ!ដាក់តាមគេ ក្រោយមកខ្ញុំសរសេរក្រដាសឲ្យគេមួយដែរ បើថាគេអាចដឹង គេមានអ្នករកបងប្អូនច្រើនណាស់ដាក់នៅចុងកុំព្យូទ័រអង្គការអីមួយទេ កាលនឹងខ្ញុំនៅកូលាបទី១ ។ ក្រោយមក ខ្ញុំបានដាក់ពាក្យទៅរកប្អូននេះដែរ បើសិនណាឃើញមានឈ្មោះនឹង គេនឹងជម្រាបប្រាប់ខ្ញុំ ប៉ុន្តែក្រោយមកបាត់ដំណឹងឈឹងរហូតដែរ ។ អង្គការនឹងក្រោយមកក៏បានដូចជាបិទទៅវិញ ក្រោយពីអ៊ុកគាត់បោះឆ្នោតហើយ ។

ដារ៉ា ៖ បើសិនជាបងចង់ស្វះស្វែងរកប្អូនបង២នាក់នឹង បងអាចសរសេរជាសាច់រឿងអី មិនមែនសាច់រឿង សរសេរជាប្រវត្តិអីមួយទាក់ទងទាំងប្អូនបងទាំង២នាក់នឹង ដូចបងរៀបរាប់ប្រាប់ខ្ញុំមិញនឹង ។ ហើយដាក់ជាសំបុត្រមកផ្ញើមកខ្ញុំក៏បាន ពួកខ្ញុំអាចចុះនៅក្នុងទស្សនាវដ្ដីជួយផ្សព្វផ្សាយ ដូចថាសំណាងល្អក្រែងលមានអ្នកណាដូចថាដឹងប្រវត្តិអីអញ្ចឹង ដឹងថាប្អូនបងប្រវត្តិអាចជូនដំណឹងមកបងវិញដែរ ។ បើសិនជាបងមានពេលណាមួយ បង

សរសេរជាសាច់រឿងនឹងមួយ ជួយរកបងប្អូនខ្ញុំនឹង ហើយបងយកឲ្យពួកខ្ញុំចុះនៅក្នុងទស្សនាវដ្ដី ពួកខ្ញុំចុះជូន។ យ៉ាងម៉េចដែរ?

ចាន់ផល : បាទ! ចាំមើលថ្ងៃខ្ញុំណាទំនេរខ្ញុំសរសេរខ្លួនឯង។

ដារ៉ា : : សរសេរខ្លួនឯងវាច្បាស់ជាង បងលម្អិតជាងថាមានបងប្អូនប៉ុន្មានហើយបែកគ្នាយ៉ាងម៉េចៗ។ ខ្ញុំដូចជាអស់សំនួរប៉ុននឹងហើយ បើជាទេវិទ្ធមានសំនួរអីបន្ថែមយ៉ាងម៉េចៗអាចសួរបន្ថែម។

ទេវិទ្ធ : បងខ្ញុំចង់សួរបញ្ជាក់បន្ថែមទៀត ពេលឆ្នាំ៨០ជាងហើយ ពេលវៀតណាមយកចេញមកពីទួលស្លែងហើយ យកទៅដាក់នៅមជ្ឈមណ្ឌល?

ចាន់ផល : អត់ទាន់ទេ ខ្ញុំនៅជាមួយកងទ័ពវៀតណាម។

ទេវិទ្ធ : អូ!នៅទ័ពវៀតណាម នៅប៉ុន្មានឆ្នាំ?

ចាន់ផល : នៅទ័ពវៀតណាមប្រហែលជាងម៉ាឆ្នាំ។

ទេវិទ្ធ : នៅកន្លែងណាកាលនឹង?

ចាន់ផល : ទៅនៅទ័ពក្រុងហើយ គេជូរទីតាំងដាក់នៅក្នុងចំការនៅក្នុងចំការដូងៗ នៅសាលាយើងពល់ថ្ងៃគេហៅសាលាកសិកម្ម។

ទេវិទ្ធ : ភូមិន្ទកសិកម្ម។

ចាន់ផល : បាទ! ភូមិន្ទកសិកម្ម ក្រោយមកទៀត បានលោកឈ្មោះនីតា កែវចិន្ដា គាត់អតីត បើតាមខ្ញុំដឹង គាត់នឹងដូចជាគណៈប្រតិភូនៅក្នុងបក្សក្រុង ហើយក្រោយមកបានគាត់យកខ្ញុំទៅនៅផ្ទះគាត់ ហើយជួបអីមីងម្នាក់គាត់ជួយមើលពួកខ្ញុំនឹង ដោយឲ្យខ្ញុំចូលរៀននៅសាលាវត្តកោះនៅភ្នំពេញនឹង។

ទេវិទ្ធ : មីងនឹងឈ្មោះអីដែរ?

ចាន់ផល : មីងនឹងឈ្មោះប៉ែន, អេង ប៉ែន, ចេន ប៉ែន ញ៉ែនៗ បាទ! ប៉ែន ញ៉ែន។

ទេវិទ្ធ : គាត់កាលនឹងអាយុប៉ុន្មាន៨០ជាង?

ចាន់ផល : គាត់នឹងប្រហែលអាយុ៤៥។

ទេវិទ្ធ : ៤៥អញ្ចឹងឥឡូវអាច៦០ជាង?

ចាន់ផល : បាទ! គាត់មើលពួកខ្ញុំនឹង ហើយខ្ញុំទៅរៀន។

ដារ៉ា : : ឈ្មោះប៉ែនអី?

ចាន់ផល : មីងមួយដែលអ្នកមើលខ្ញុំនឹង គាត់ឈ្មោះ ប៉ែន ញ៉ែន, ប៉ែន អេន។

ទេវិទ្ធ :	ប៉ែន ញៀន, ប៉ែន អេន?

ចាន់ផល :	បាទ! ប្រហែលប៉ែន អេន, ប៉ែន ញៀន មិនចាំច្បាស់ទេ ដឹងថាគាត់បានប្រៀនប្រដៅឲ្យទៅរៀនទៅអី គាត់មើលថែរក្សា ខ្ញុំរៀននៅសាលាវត្តកោះដិតមុខផ្ទះតាកែវចិន្តា ។ ដល់ក្រោយមកទៀត នៅថ្ងៃមួយមានពិធីបុណ្យមួយនៅក្នុងវាំងនឹង ថាលោកតាកែវចិន្តានឹង គាត់បានហៅ គាត់បានជិះឡានមើលពួកខ្ញុំនឹងទៅមើលកុននឹង ដែលគាត់ជិះបើសិនខ្ញុំចាំបាន ដែលគាត់ប្រមូលពួកខ្ញុំប៉ុន្មាននាក់នឹងឯង តែខ្ញុំហើយនឹងប្អូនខ្ញុំ៣នាក់ទេដែលអាចដើរបាន អាតូចទៀតអត់ទាន់ដើរបានទេ ហើយមីងស្រីនឹងគាត់ជួយមើល ហើយគាត់យកចូលទៅផ្ទះសម្ដេចហ៊ុនសែននឹង ។ គាត់យកខ្ញុំទៅលេងនៅផ្ទះសម្ដេចហ៊ុន សែននឹង ហើយឲ្យខ្ញុំជម្រាបសួរលោកនឹងហើយកាលខ្ញុំនេះ កាលរៀននោះខ្ញុំនៅស្ទើរ អត់ចេះជម្រាបសួរការគួរសមនឹងណា ហើយទៅសម្ដេចហ៊ុន សែនថាលោកឯងយកក្មេងនឹងមកនៅអញ្ចឹងវាអត់បានរៀនសូត្រវាអត់ចេះអត់អីទេ អត់ចេះការគួរសមអញ្ចឹងទេ ។ អញ្ចឹងលោកឯងយកទៅដាក់កុមារកំព្រាមានលោកគ្រូបង្ហាត់ បង្ហាញ ។ អញ្ចឹងបានក្រោយមកលោកតាកែវ ចិន្តា យកខ្ញុំទៅគេមានពិធីបុណ្យអីគេ គេទៅបញ្ចាំងនៅវាំងនឹងវាំងយើងរាល់ថ្ងៃនេះ ហើយបន្ទាប់មកស្អែកខានស្អែកក្រោយមក នៅបានម៉ាអាទិត្យបានគាត់យកខ្ញុំទៅដាក់កុមារកំព្រាកូលាបទី២ មជ្ឈមណ្ឌលកូលាបទី២ ។ ហើយបានរៀននៅទីនោះ បានរដ្ឋគេផ្គត់ផ្គង់ឲ្យរៀនសូត្រ មានសំលៀកបំពាក់ មានម៉ោងហូបនឹង ។

ទេវិទ្ធ :	កូលាបទី២នៅណា?

ចាន់ផល :	នៅក្បែរសាលាអង់អេងយើងនោះ កាលពេលនោះនៅឆ្នាំ៨០ជាង ប្រហែលនៅឆ្នាំ៨២ ៨៣, ១៩៨២-៨៣ ។

ទេវិទ្ធ :	ហើយនៅក្នុងមជ្ឈមណ្ឌលកុមារកំព្រា កាលនឹងអ្នកណាគេអ្នកមើលបងកាលនឹងកូលាបទី២?

ចាន់ផល :	មានលោកគ្រូ អ្នកគ្រូ ខ្ញុំស្គាល់បាន លោកគ្រូ ឡាយ អ៊ឹម លោកគ្រូមុំ លាង លោកគ្រូឈឹម សុវណ្ណ ហើយនឹងលោកគ្រូដទៃទៀត ដូចលោកគ្រូឡាយ សយ ។

ទេវិទ្ធ :	ហើយសព្វថ្ងៃអាចជួបគាត់?

ចាន់ផល :	បាទ! លោកគ្រូមុំ លាង ប្រហែលជាជួនគាត់ៗនៅរាល់ថ្ងៃគាត់នៅធ្វើការនៅសង្គមកិច្ចយើងលោកគ្រូឡាយ សយ ។

ទេវិទ្ធ :	សង្គមកិច្ចនៅខាងណាវិញ?

ចាន់ផល ៖ សង្គមកិច្ចយើងនៅជិតវត្តមហាមន្ត្រី។ ហើយខស្សរាប់ជួបលោកគ្រូអ្នកគ្រូ ជាពិសេសលោកគ្រូ ឡាយ អ៊ីម និងលោកគ្រូ មុំ លាង ខស្សរាប់ជួបជាងគេ សព្វថ្ងៃខ្ញុំចូលទៅលេងគាត់ម្តងម្កាល ហើយនឹងលោកគ្រូអីឈ្មោះ ហ៊ា ភាគច្រើនអត់ចាំគាត់។

ទេវិទ្ធ ៖ បង លោកតាកែវ ចិន្តា គាត់ស្លាប់ដែរ មានដឹងដែរ?

ចាន់ផល ៖ ខ្ញុំដឹង ខ្ញុំបានទៅបុណ្យសពគាត់នៅរណសិរ្ស មន្ទីររណសិរ្សនៅជិតតុលាការក្រុងយើងរាល់ថ្ងៃ ខ្ញុំបានទៅបុណ្យសពហែរទៅបូជានៅវត្តព្រះពុទ្ធ។

ទេវិទ្ធ ៖ ឆ្នាំណា?

ចាន់ផល ៖ ដូចឆ្នាំ បាទ! ដូចឆ្នាំ៨៧-៨៨ខ្ញុំនៅចាំបាន។

ទេវិទ្ធ ៖ អ្នកនៅផ្ទះជាមួយលោកគ្រូកែវ ចិន្តានឹង ស្គាល់បងទាំងអស់គ្នាទេ មើលទៅសព្វថ្ងៃសាច់ញាតិ?

ចាន់ផល ៖ បាទ! កូនៗគាត់ស្គាល់ខ្ញុំច្រើនគ្នាដូចបងផល្លា, អាច្រមក់ ស្គាល់ទាំងកូនគាត់ ហើយត្រកូលមានកែវ ដូចកែវ ផល្លា, កែវ ផល្លី។

ទេវិទ្ធ ៖ តែសព្វថ្ងៃគាត់នៅ?

ចាន់ផល ៖ សព្វថ្ងៃឮសួរថាគាត់នៅឬស្សីកែវយើង នៅខ័ណ្ឌឬស្សីកែវ ជិតកាវ៉ាសាំងឬស្សីកែវ។

ទេវិទ្ធ ៖ អញ្ចឹងមានន័យថាលោកកែវ ចិន្តា គាត់ស្លាប់ទៅ បងអត់ដែលបានទាក់ទងនឹងគ្រួសារនឹងទេ?

ចាន់ផល ៖ បាទ! បាត់រយៈឈឹងទៅ ដោយសារគាត់ប្តូរទីកន្លែងផ្ទះ ខ្ញុំអត់ធ្លាប់ជិះកង់កាត់អីដែរចូលលេងម្តងម្កាលតាំងគាត់នៅរស់នឹង ដល់ពេលគាត់ស្លាប់ទៅ អត់បានទៅជួប។ ជិះកាត់អត់ហ៊ានចូល ដូចថាមើលអត់ឃើញគាត់អញ្ចឹង ខ្ញុំអត់ហ៊ានចូល។

ទេវិទ្ធ ៖ បើត្រឡប់មកខាងពេលបងនៅគុកទួលស្លែងវិញ អាចចាំបានទេ ប៉ុន្មានខែដែរនៅក្នុងរយៈពេលនឹងបានវៀតណាមចូលមកដល់?

ចាន់ផល ៖ វាយូរដែរ បានខ្ញុំអត់បានចាំ ប្រហែលខ្ទង់៣-៤ខែនឹង បើតាមមើលវារដូវនឹង រដូវប្រាំងសុទ្ធ វាអត់មានភ្លៀងម្តងៗ។

ទេវិទ្ធ ៖ ចុះនៅពេល បងខ្ញុំចាំបងនិយាយបានមិញថា បងឃើញម្តាយបងនៅលើគុក កាលដែលបងឃើញនឹង គាត់នៅណា ហើយបងនៅណា?

ចាន់ផល ៖ កាលនឹងគាត់នៅឈរលើអគារនឹង នៅជាន់ទី២ នៅបន្ទប់ទី២គាត់សំឡឹងមើលខ្ញុំខាងក្រោមហើយខ្ញុំសំឡឹងមើលគាត់។

ទេវិទ្ធ ៖ អគារណា?

ចាន់ផល ៖ អគារយើងចូលទៅអគារទី៣ អគារសេ ។

ទេវិទ្ធ ៖ អគារសេ?

ចាន់ផល ៖ បាទ!

ទេវិទ្ធ ៖ ហើយបងកាលនឹងបងនៅខាងណាវិញ នៅខាងក្រោយ ខាងមុខ នៅខាងណាវិញ?

ចាន់ផល ៖ នៅខាងក្រោយកន្លែងគេដាក់កុមារនឹង ខាងក្រោយនឹងមានរោងជាង ។

ទេវិទ្ធ ៖ ហើយគាត់ពេលនឹងគាត់ឃើញបងទេ ឬក៏ពេលនឹងបងឃើញគាត់?

ចាន់ផល ៖ គាត់ឃើញខ្ញុំ ខ្ញុំឃើញគាត់ដែរ តែរំភ្នែកសំឡឹងគ្នាទៅវិញទៅមក ។

ទេវិទ្ធ ៖ គាត់អត់មាននិយាយស្រែកអី?

ចាន់ផល ៖ បាទ! ដោយគាត់អត់ហ៊ានស្រែកតមកខ្ញុំ សួរខ្ញុំយ៉ាងម៉េចទេ ដោយសារមានអ្នកយាម
នៅខាងក្រៅ ឬមួយយ៉ាងម៉េចនៅឆ្ងាយគាត់ ហើយខ្ញុំអត់ហ៊ានហៅសួរទៅគាត់ទៅ ។

ទេវិទ្ធ ៖ បងអត់ហ៊ានហៅដែរ?

ចាន់ផល ៖ បាទ! គ្រាន់តែប្អូនៗយំចង់ ដូចថាវាយំចង់ទៅជួបគាត់អញ្ចឹង ។

ទេវិទ្ធ ៖ ឃើញតែម្តងនឹងទេ?

ចាន់ផល ៖ បាទ! ឃើញម្តងនឹងនៅពេលថ្ងៃត្រង់នឹងរហូត ។ ដល់ពេលរំលងបានខាងស្អែកឡើង ក៏
បាត់មុខគាត់រហូតទៅ ។

ទេវិទ្ធ ៖ ឃើញនឹងចំងាយប៉ុន្មានទៅ?

ចាន់ផល ៖ បើតាមខ្ញុំបច្ចុប្បន្ន ប្រហែល៣០-៤០ម៉ែត្រពីអគារលើមកខ្ញុំឈរដីក្រោម ហើយ
ចំងាយ ។

ទេវិទ្ធ ៖ គាត់ជាន់ទី២?

ចាន់ផល ៖ បាទ! គាត់ជាន់ទី២ ហើយយើងឈរនឹងប្រហែលខ្ពង់៣០ម៉ែត្រ ៤០ម៉ែត្រ ។

ទេវិទ្ធ ៖ យើងឃើញគាត់ជាប់ឃ្នោះ ឃើញអី មានឃើញទេ ឬឃើញតែរូបគាត់ទេនៅមាត់បង្អួច
នឹង?

ចាន់ផល ៖ បាទ! នៅមាត់បង្អួច អត់មានអីជាប់ ឈរមកឃើញតែរូបពាក់កណ្តាលខ្លួន នៅតាម
បង្អួច ដូចអត់មានឃើញ ។

ទេវិទ្ធ ៖ បើត្រឡប់ទៅក្រោយវិញបន្តិចទៀត ឪពុកម្តាយបងមុនពេលចាប់នឹង គេចាប់ឪពុកបង
មុន?

ចាន់ផល ៖ បាទ!

ទេវិទ្ធ ៖ កាលនឹងគាត់ធ្វើអីដែរ ដឹងថាគេថាប្រាប់ថាគាត់ខុសអីបានគេចាប់ទៅអញ្ចឹង?

ចាន់ផល ៖ កាលមុនគាត់ធ្វើជាកម្មករសំណង់រទេះភ្លើងយើង ។

ទេវិទ្ធ ៖ កាលនឹងនៅសហករណ៍មួយណា?

ចាន់ផល ៖ នៅសហករណ៍យើងនៅស្រុកអីនៅកំពង់ស្ពឺ នៅឃុំត្រែងត្រយឹងនេះ ។

ទេវិទ្ធ ៖ សហករណ៍ត្រែងត្រយឹង?

ចាន់ផល ៖ បាទ!

ទេវិទ្ធ ៖ គាត់ជាកម្មករទេនោះ?

ចាន់ផល ៖ បាទ!

ទេវិទ្ធ ៖ ប៉ុន្តែគេមកចាប់អីអញ្ចឹង មានពូអ្នកដែលគេឃើញ ដែលគេប្រាប់នឹង គេមានប្រាប់ហេតុអី គេចោទស្អី ឬមានធ្វើខុសអី?

ចាន់ផល ៖ អត់មានដឹងថាខុសអីទេ ខ្ញុំអត់ដឹងថាខុសអីទេ គ្រាន់តែឬសួរគេហៅគាត់ទៅៗ បានពូខ្ញុំរត់មកប្រាប់ម្តាយ ។

ទេវិទ្ធ ៖ ថាគេចាប់ទៅហើយ?

ចាន់ផល ៖ បាទ! ចាប់ទៅហើយ ។

ទេវិទ្ធ ៖ គាត់មានប្រាប់ថា គេចាប់ទៅណា អ្នកណាយកទៅណា អ្នកណាមកចាប់ទេមានទេ?

ចាន់ផល ៖ បាទ!អត់ដឹងដែរ ប៉ុនគ្រាន់លួចរត់មកៗប្រាប់ម្តាយខ្ញុំ ដល់រត់ឡើងប្រញាប់តាមមើលរត់ឡើងប្រញាប់ដូចខ្លាចគេឃើញអញ្ចឹង ។

ទេវិទ្ធ ៖ ប្រហែលរយៈពេលប៉ុន្មាន ក្រោយមកបានគេមកហៅបង គេមកយកម្តាយបងទៀត?

ចាន់ផល ៖ កន្លងប្រហែល៣ខែក្រោយមក ។

ទេវិទ្ធ ៖ ចុះមកនឹង ពេលគេហៅឡើងឡាននឹង គេមានប្រាប់ថាម៉េចទេ?

ចាន់ផល ៖ មានគេនិយាយៗតទល់ម្តាយខ្ញុំ ប៉ុន្តែខ្ញុំអត់មានបានចាប់អារម្មណ៍នឹងពាក្យសម្តីនិយាយធម្មតាក្មេងចេះដើរជុំវិញគាត់អត់ទៅណាទេ ។

ទេវិទ្ធ ៖ នៅក្នុងរោងដែលគេធ្វើឃ្នោះនឹងមានមនុស្សប៉ុន្មាននាក់ដែរ?

ចាន់ផល ៖ មានចាស់ៗប្រហែលជាជាង៤-៥នាក់ ។

ទេវិទ្ធ ៖ មានពីណាខ្លះ?

ចាន់ផល ៖ ចាំជាងគេ គឺឈ្មោះតាគង់ជាងគេ ដល់ក្រោយមកពេលបែកហើយ គាត់ឈ្មោះតាគង់ គាត់និយាយប្រាប់ដែរ ឈ្មោះតាគង់, តាជា ហើយមិនដឹងប៉ុន្មាននាក់ទៀតទេ ។ ដឹងថាតាគង់, តាជា ប៉ុន្តែខ្ញុំចាំបានចាស់ៗនឹងមាន៤-៥នាក់ សុទ្ធតែជាជាងៗទាំងអស់ មានជាងចំលាក់ មានជាងឈ្មោះ មានជាងឈើជួសជុលបន្តិច ទ្វារបាក់បែក សុទ្ធតែជាជាងចាស់ៗនឹង ។ ពេលខ្ញុំស្គាល់ អាយុប្រហែលជា៥០ជាងហើយ ។

ទេវិទ្ធ ៖ ប៉ុន្តែក្រោយមកទៀត បងជួបតែតា?

ចាន់ផល ៖ តាគង់មួយទេ ។

ទេវិទ្ធ ៖ អ្នកផ្សេងទៀត?

ចាន់ផល ៖ ប៉ុនបច្ចុប្បន្នឥឡូវ គាត់ស្លាប់បាត់ទៀតហើយ ។

ទេវិទ្ធ ៖ បងដឹងថាស្លាប់មកពី?

ចាន់ផល ៖ ខ្ញុំដោយសារខ្ញុំទៅលេងកន្លែងសារមន្ទីរនឹងម្ដងៗ ខ្ញុំតែងតែសួររកអ្នកធ្វើការនៅនឹង សួររកតាគង់នឹង ថាតាគង់គាត់រីត្រែតហើយ ។

ទេវិទ្ធ ៖ អ្នកណាដែលស្គាល់បងច្បាស់តាំងពីឆ្នាំ៨០ជាងមកនៅទួលស្លែងនឹង?

ចាន់ផល ៖ ដូចបងផល្លា ។

ទេវិទ្ធ ៖ ឈ្មោះអីផល្លា?

ចាន់ផល ៖ អឺ! ដូចប៉ែន ផល្លា ។

ទេវិទ្ធ ៖ គាត់ឥឡូវនៅទួលស្លែងទៀត?

ចាន់ផល ៖ ប៉ែន ផល្លា, ប៉ែន ជីវី ហើយនឹង ។ ហើយនឹងដូចជាដូចបងមីងមួយប៉ែន ញ៉ែមនឹង មកដល់ឥឡូវគាត់ស្លាប់បាត់ហើយ ដោយសារលើសឈាម ស្លាប់ច្រើនឆ្នាំហើយ គាត់បានស្លាប់ហើយ គាត់ស្លាប់ច្រើនឆ្នាំហើយ ។

ទេវិទ្ធ ៖ មីងដែលមើលបងនឹង?

ចាន់ផល ៖ បាទ! មីងដែលគាត់ចំណាស់ ខ្ញុំកូនក្មេង ។

ដារ៉ា ៖ ៖ ចុះនៅកូលាបនៅអី បងមានចាំឈ្មោះលោកគ្រូ អ្នកគ្រូនៅជាមួយបង?

ចាន់ផល ៖ បាទ! ចាំ ខ្ញុំជម្រាបគាត់ហើយៗ ។

ទេវិទ្ធ ៖ បង ដូចអត់មានអីសួរបងទៀតទេ តែចុងក្រោយបងចង់សួរ ក្រែងលរបងមានអីចង់និយាយបន្ថែម បងមាននឹកឃើញអីដែលខ្ញុំអត់បានសួរអញ្ចឹង ។ មានអីដែលបងគិតថា

ចាប់អារម្មណ៍ ឧទាហរណ៍ឃើញគេសម្លាប់ ឃើញអីអញ្ចឹងនៅក្នុងទួលស្លែង ឃើញវាយដំ ឃើញអីអញ្ចឹង?

ចាន់ផល : បាទ! ឃើញវ៉ៃដំ ឃើញឮសូរសំរែក ឃើញគេសំឡុតអ្នកទោសទៅ ដូចមានការទាត់ធាក់ ដូចថាគ្នាវិលមុខអញ្ចឹង ដើរអត់ត្រង់ផ្លូវ ដើរជំពប់ជើងដួលទៅទាត់ធាក់គ្នាវ៉ៃគ្នាថែមវ៉ៃដំពីក្រោយ ។

ទេវិទ្ធ : មានដែលឃើញគេសម្លាប់មនុស្សអីម៉ង់នៅទួលស្លែង?

ចាន់ផល : បាទ! អត់សូវស្គាល់ទេ ដោយសារពេលដែលចេញដំណើរដើរទៅណាម្តងៗ ទ្វារខាងក្រោយនឹងត្រូវបានបិទ យើងអត់ឆ្លងកាត់បានទេ ។

ទេវិទ្ធ : សំរែកឮរាល់យប់ ឬរាល់ថ្ងៃតែម្តង?

ចាន់ផល : យប់អត់ឮទេ ឮសូរតែថ្ងៃពេលម៉ោង៨-៩, ៧-៨-៩ ឮសូរសំរែកហើយ ម៉ោង១០ព្រឹកហើយ ម៉ោង១០ព្រឹក ហើយនឹងល្ងាចចាប់ពីម៉ោង២-៣កន្លះ-៤ លែងឮហើយ ។ អញ្ចឹងឮដែរ ដល់ពេលក្រោយមក បាត់ស្ងាត់ នៅពេលយប់លែងឮសំរែកអីទាំងអស់ ។

ដារ៉ា : : យប់គេដេក?

ចាន់ផល : ប៉ុន្តែ នៅពេលព្រឹកម្តងៗ ខ្ញុំឃើញមានឡានដឹកសាកសពចេញទៅ ដូចថាមានការវ៉ៃដំ បើតាមឮសូរសំរែក មានការវ៉ៃដំអញ្ចឹងរហូតមានរបួសស្នាមរហូតដល់ស្លាប់អញ្ចឹងមានឡានមួយដឹកសម្រាប់ដឹកសាកសពចេញៗទៅក្រៅៗគុកទៅ ប៉ុនដឹងដឹកយកទៅណាទេ ខ្ញុំអត់ដឹង ។

ដារ៉ា : : ចុះបងភូមិនេះគេហៅភូមិអី?

ចាន់ផល : ភូមិនេះគេហៅភូមិតាំងតាឡាត់ ឃុំក្សាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ដារ៉ា : : ភូមិតាំងតាឡាត់ ឃុំក្សាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ អញ្ចឹងអាស្រ័យថាផ្ទះសម្បែងនៅវិញ?

ចាន់ផល : ខ្ញុំនៅសង្កាត់បឹងដំពន់ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

ដារ៉ា : : ផ្ទះលេខប៉ុន្មាន ផ្លូវលេខប៉ុន្មាន?

ចាន់ផល : ផ្ទះនេះដូចអត់ទាន់មានឡានធ្វើ នៅក្នុងសហគមន៍គេ ក្រោយមកគេប្រគល់ទៅសាលាក្រុងកន្លែងនឹង ។

ទេវិទ្ធ : ផ្លូវអី?

ចាន់ផល ៖ អាផ្លូវយើងទៅទំនប់នឹងមកចុះមានរោងចក្រកាត់ដេរមួយឈ្មោះ ជីឡាងហ្វូច នៅក្រោយរោងចក្រនឹង គេហៅសហគមន៍គេ សហគមន៍ជីត្រាំ។

ដារ៉ា ៖ ៖ បងមានកូនចៅប៉ុន្មាននាក់ដែរ?

ចាន់ផល ៖ បាទ! ខ្ញុំមានកូនចៅ២នាក់។

ដារ៉ា ៖ ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ចាន់ផល ៖ ស្រីទាំង២។

ដារ៉ា ៖ ៖ អាបងគេអាយុប៉ុន្មាន?

ចាន់ផល ៖ អាបងគេអាយុ១២ឆ្នាំ អាប្អូនវាអាយុ៦ឆ្នាំ។

ដារ៉ា ៖ ៖ គ្រួសារបងឈ្មោះអីដែរ?

ចាន់ផល ៖ ប្រពន្ធខ្ញុំឈ្មោះ ឡាយ សារឿន។

ដារ៉ា ៖ ៖ បងដល់ពេលថ្ងៃអាយុប៉ុន្មាន?

ចាន់ផល ៖ ខ្ញុំអាយុ៣៩ឆ្នាំ។

ដារ៉ា ៖ ៖ អញ្ចឹងប៉ុននឹង ខ្ញុំអស់ហើយប៉ុននឹងបង ខ្ញុំអរគុណបងច្រើនដែលបានផ្តល់ព័ត៌មាន។

ចាន់ផល ៖ បាទ!

«ចប់»